Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized



ទិដ្ឋភាពរួម

# កម្ពុជា

## រក្សាកំណើនរឹងមាំ ដើម្បីអត្ថប្រយោជន៍ទាំងអស់គ្នា

ការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ

ក្រុមធនាគារពិភពលោក

កូនសៀវភៅនេះ ពណ៌នាអំពីទិដ្ឋភាពរួមនៃការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ - ការរក្សាកំណើនដើម្បីអត្ថប្រយោជន៍ទាំងអស់គ្នា។ របាយការណ៍ចុងក្រោយទាំងមូល រួមទាំងឯកសារយោងអាចរកបាននៅ៖

http://documents.worldbank.org/curated/en/620151496155751423/Cambodia-Sustaining-strong-growth-for-the-benefit-of-all

នេះគឺជាស្នាដៃរបស់បុគ្គលិកធនាគារអន្តរជាតិសម្រាប់ការកសាងឡើងវិញ និងអភិវឌ្ឍន៍ / ធនាគារពិភពលោក។ របកគំហើញ ការបកស្រាយ និងសេចក្តីសន្និដ្ឋានដែលបង្ហាញនៅក្នុងឯកសារនេះមិនឆ្លុះបញ្ចាំងទស្សនៈរបស់នាយកប្រតិបត្តិធនាគារពិភពលោក ឬរដ្ឋាភិបាលដែលពួកគេតំណាងនោះទេ។ ធនាគារពិភពលោកមិនធានាភាពត្រឹមត្រូវនៃទិន្នន័យដែលមាននៅក្នុងសំណេរនេះឡើយ។ ព្រំប្រទល់ ពណ៌ និមិត្តសញ្ញា និងព័ត៌មានផ្សេងទៀតដែលបានបង្ហាញលើផែនទីណាមួយនៅក្នុងសំណេរនេះពុំមែនមានន័យថាជាការវិនិច្ឆ័យពីខាងធនាគារពិភពលោក ទាក់ទងនឹងស្ថានភាពស្របច្បាប់នៃដែនដីណាមួយ ឬការយល់ព្រម ឬការទទួលយកដែនកំណត់ទាំងនោះឡើយ។ គ្មានអ្វីក្នុងសៀវភៅនេះបង្កើត ឬត្រូវបានចាត់ទុកថាជាការដាក់កម្រិត ឬការលើកលែងឯកសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ធនាគារពិភពលោកឡើយ ដែលទាំងអស់នេះត្រូវបានរក្សាសិទ្ធិជាពិសេស។

**ប្រភព**

សូមបញ្ជាក់ប្រភពសំណេរនេះដូចតទៅ: World Bank. 2017. *Cambodia - Sustaining strong growth for the benefit of all. Overview*. Washington, D.C. : World Bank Group. (ធនាគារពិភពលោក ឆ្នាំ 2017។ កម្ពុជា - ការរក្សាកំណើនរឹងមាំដើម្បីអត្ថប្រយោជន៍ទាំងអស់គ្នា។ ទិដ្ឋភាពរួម។ វ៉ាស៊ីនតោន ឌីស៊ី ក្រុមធនាគារពិភពលោក)។

**សិទ្ធិនិងការអនុញ្ញាត**

ខ្លឹមសារនៅក្នុងសៀវភៅនេះត្រូវបានរក្សាសិទ្ធិ។ ការចម្លង និង/ឬការបញ្ជូនផ្នែកណាមួយ ឬសំណេរទាំងស្រុង ដោយគ្មានការអនុញ្ញាតអាចជាការរំលោភច្បាប់។ ធនាគារអន្តរជាតិសម្រាប់ការកសាងឡើងវិញនិងអភិវឌ្ឍន៍ / ធនាគារពិភពលោកលើកទឹកចិត្តដល់ការផ្សព្វផ្សាយសំណេររបស់ខ្លួន ហើយជាធម្មតានឹងផ្តល់ការអនុញ្ញាតភ្លាមៗឱ្យចម្លងនូវផ្នែកនានានៃសំណេរនេះ។

សម្រាប់ការអនុញ្ញាតឱ្យថតចម្លងឬបោះពុម្ពឡើងវិញនូវផ្នែកណាមួយនៃរបាយការណ៍នេះ សូមផ្ញើសំណើដោយមានព័ត៌មានពេញលេញទៅកាន់ Copyright Clearance Center, Inc.
222 Rosewood Drive, Danvers, MA 01923, USA
ទូរស័ព្ទ: 978-750-8400 ទូរសារ: 978-750-4470
http: //www.copyright.com/

សូមផ្ញើរាល់សំណួរដ៏ទៃទៀតស្តីពីសិទ្ធិនិងអាជ្ញាប័ណ្ណ រួមទាំងសិទ្ធិ បុត្រសម្ព័ន្ធ ទៅកាន់ការិយាល័យបោះផ្សាយរបស់ធនាគារពិភពលោក

1818 H Street NW
Washington, DC 20433, USA
ទូរសារ: 202-522-2422
អ៊ីម៉េល: pubrights@worldbank.org

រចនាខាងក្នុងដោយ: Florencia Micheltorena, ប៊ុយណូហ្សៃរ៍ (Buenos Aires), ប្រទេសអាហ្សង់ទីន

# អក្សរកាត់

| | | |
|---|---|---|
| **ASEAN** | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CCT** | conditional cash transfer | ការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ |
| **CSES** | Cambodia Socio-Economic Survey | ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា |
| **CSO** | civil society organization | អង្គការសង្គមស៊ីវិល |
| **EU** | European Union | សហភាពអឺរ៉ុប |
| **FDI** | foreign direct investment | វិនិយោគផ្ទាល់ពីបរទេស |
| **GDP** | gross domestic product | ផលិតផលក្នុងស្រុកសរុប |
| **GNI** | gross national income | ចំណូលជាតិសរុប |
| **HEF** | health equity fund | មូលនិធិសមធម៌សុខាភិបាល |
| **HIV/AIDS** | human immunodeficiency virus/acquired immune deficiency syndrome | វីរុសហ៊ីវ/ជំងឺអេដស៍ |
| **HR** | human resource | ធនធានមនុស្ស |
| **IWRM** | integrated water resources management | ការគ្រប់គ្រងធនធានទឹកចម្រុះ |
| **LDC** | least developed country | ប្រទេសអភិវឌ្ឍន៍តិចតួច |
| **LGBTI** | lesbian, gay, bisexual, transgender, and/or Intersex | ស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ភេទទាំងពីរ ខ្ទើយនិង/ឬ អ្នកមានភេទមិនច្បាស់ថាស្រីឬប្រុស |
| **L-MIC** | lower middle-income country | ប្រទេសមានចំណូលមធ្យមកម្រិតទាប |
| **MDG** | Millennium Development Goal | គោលដៅអភិវឌ្ឍន៍ប្រចាំសហសវត្សរ៍ |
| **MFI** | microfinance institutions | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| **NDC** | Nationally Determined Contribution | ការរួមចំណែកថ្នាក់ជាតិដែលបានកំណត់ |
| **NGO** | non-governmental organization | អង្គការមិនមែនរដ្ឋាភិបាល |
| **ODA** | official development assistance | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| **OOP** | out-of-pocket | ចំណាយប្រាក់ហោប៉ៅ |
| **PIM** | public investment management | ការគ្រប់គ្រងវិនិយោគសាធារណ: |
| **PPP** | public-private partnership | ភាពជាដៃគូរវាងវិស័យសាធារណ:និងឯកជន |
| **PPP** | purchasing power parity | សមភាពអំណាចទិញ |
| **RBS** | risk-based supervision | ការត្រួតពិនិត្យផ្អែកលើហានិភ័យ |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **SCD** | Systematic Country Diagnostic | ការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណ:ជាប្រព័ន្ធ |
| **STEM** | science, technology, engineering, and mathematics | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| **TB** | tuberculosis | របេង |
| **TVET** | technical and vocational education and training | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវ: |
| **US** | United States | សហរដ្ឋអាមេរិក |
| **USD** | United States dollar | ដុល្លារអាមេរិក |

# មាតិកា

**សេចក្ដីថ្លែងអំណរគុណ** 3

**ទិដ្ឋភាពរួម** 7

## បញ្ជីរូបភាព

រូបលេខ 1. ផលិតភាពពលកម្មមានកំណើនទាបជាងគូប្រជែង (ខាងឆ្វេង) មួយផ្នែកគឺដោយសារឯកទេសភាវូបនីយកម្មលើឧស្សាហកម្មដែលប្រើទុនតិច(ខាងស្ដាំ) 10

រូបលេខ 2. កម្ពុជានៅមានភាពយឺតយ៉ាវនៅឡើយលើទិដ្ឋភាពមួយចំនួននៃភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច 11

រូបលេខ 3. អត្រាប្រេវ៉ាឡង់ជម្ងឺក្រិនមានកម្រិតខ្ពស់ក្នុងចំណោមអ្នកក្រ (ខាងឆ្វេង) ហើយកម្ពុជាដើរមិនទាន់ប្រទេសដទៃទៀតក្នុងការទទួលបានទឹកស្អាត និងសេវាអនាម័យ (ខាងស្ដាំ) 13

រូបលេខ 4. ប្រៀបធៀបជាមួយប្រទេសដទៃ ប្រទេសកម្ពុជាប្រឈមមុខ និងមានភាពងាយរងគ្រោះខ្ពស់ជាខ្លាំងចំពោះគ្រោះមហន្តរាយនានា 14

រូបលេខ 5. កម្ពុជាមានដំណាក់កាលបង្កើនទុនលឿនបំផុត ក្នុងចំណោមប្រទេសដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា (ខាងឆ្វេង); ទំហំឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង (ខាងស្ដាំ) 16

## បញ្ជីតារាង

តារាងលេខ 1: លំអានការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ និងការកំណត់វិស័យអាទិភាពសម្រាប់អភិវឌ្ឍន៍ 18

| | IBRD | IFC | MIGA |
|---|---|---|---|
| អនុប្រធានប្រចាំតំបន់ | វិចតូរៀ ក្វាក្វា (Victoria Kwakwa) | ឌីមីទ្រីស ស៊ីតសៃរ៉ាហ្គោស (Dimitris Tsitsiragos); នីណា ស្ទយល៍ជកូវិច (Nena Stoiljkovic) | គីកូ ហនដា (Keiko Honda) (EVP&CEO) |
| នាយក | អ៊ុលរិច ហ្សាចៅ (Ulrich Zachau) | វីវែក ផាថាក (Vivek Pathak) | មើលី ប៉ារ៉ូឌី (Merli Baroudi) |
| ប្រធានក្រុមការងារ | មីហ្គែល អេ. សាន់ឆេស (Miguel E. Sanchez); អូបើត ភីមហ៊ីដហ្សៃ (Obert Pimhidzai) | ដេនីញែល ស្ទ្រីត (Daniel Street); ដួង សារ៉ាក់ (Sarak Duong) | ផូល បាបួរ (Paul Barbour) |

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះគឺជាស្នាដៃរបស់ក្រុមការងារនៃក្រុមធនាគារពិភពលោកពហុវិស័យ ដែលដឹកនាំដោយលោក អូបើត ភីមហ៊ីដហ្សៃ (Obert Pimhidzai) លោក មីហ្គែល អេឌូអាដូ សាន់ឆេស ម៉ារទីន (Miguel Eduardo Sánchez Martín) និង លោក ដេនីញែល ស្ទ្រីត (Daniel Street) ។ លោកស្រី អ៊ីនហ្គូណា ដូប្រាចា (Inguna Dobraja) (ប្រធានគ្រប់គ្រងប្រចាំប្រទេសកម្ពុជា) និងលោក ដួង សារ៉ាក់ (ប្រធានសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិប្រចាំកម្ពុជា) បានផ្តល់ការគាំទ្រយ៉ាងជិតស្និទ្ធ និងដំបូន្មានដល់ក្រុមការងារ ក៏ដូចជាដល់អ្នកដឹកនាំផងដែរក្នុងអំឡុងពេលពិគ្រោះយោបល់។ របាយការណ៍នេះទទួលអត្ថប្រយោជន៍ពីការរួមចំណែកដ៏គួរឱ្យសរសើរជាខ្លាំងពី អ្នកស្រី មីនណា ហាញ់តុង (Minna Hahn Tong) (ទីប្រឹក្សា) និង អ្នកស្រី ម៉ារៀ ដាំភើត ( Maria Dumpert) (ទីប្រឹក្សា) ក្នុងការរៀបចំសេចក្តីព្រាង និងកែសម្រួល។

ក្រុមការងារនេះសូមសម្តែងនូវការដឹងគុណចំពោះការណែនាំដ៏ប្រសើរ និងការគាំទ្រយ៉ាងខ្លាំងពីលោក អ៊ុលរិច ហ្សាចៅ (Ulrich Zachau) (នាយកប្រចាំប្រទេស) លោក វីវ៉ែក ផាថាក (Vivek Pathak) (នាយកសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិប្រចាំកម្ពុជា) លោកស្រី សៀវឈីង យូ (Xiaoqing Yu) (នាយកយុទ្ធសាស្ត្រនិងប្រតិបត្តិការ) លោក ឃីឡេ អែហ្វ ឃែលហូហ្វើរ (Kyle F. Kelhofer) (ប្រធានគ្រប់គ្រងកម្មវិធីជាន់ខ្ពស់នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិប្រចាំកម្ពុជា) លោក ម៉ាធូ វើរហ្គីស (Mathew Verghis) (ប្រធានគ្រប់គ្រងផ្នែកអនុវត្ត ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ) លោក សាល់ម៉ាន ហ្សៃឌី (Salman Zaidi) (ប្រធានគ្រប់គ្រងការអនុវត្តន៍ ភាពក្រីក្រ) លោក ស៊ូឌៀ ស្ជិតធី (Sudhir Shetty) (ប្រធានសេដ្ឋវិទូ) លោក ស្ហាប៊ីហ៍ អាលី ម៉ូហ៊ីប (Shabih Ali Mohib) (ប្រធានកម្មវិធី), លោកស្រី លូ ស្គូរ៉ា (Lou Scura) (ប្រធានកម្មវិធី) និងលោក ឡាស សនឌើហ្គាដ (Lars Sondergaard) (ប្រធានកម្មវិធី)។

របាយការណ៍នេះមានមូលដ្ឋានផ្អែកលើការងារស្រាវជ្រាវនៃកំណើន និងភាពប្រកួតប្រជែង (Kazi Matin, Guillermo Arena, Theepakorn Jithitikulchai, Dilaka Lathapipat, Miguel Sánchez) ភាពក្រីក្រ និង បរិយាប័ន្ន (Obert Pimhidzai និង តុង គឹមស៊ុន ដោយមានការរួមវិភាគទានពីមិត្តរួមការងារជាច្រើននាក់) យេនឌ័រ និងនិរន្តរភាពសង្គម (Erik Caldwell, Theepakorn Jithitikulchai) និងធនធានធម្មជាតិ (Maria Dumpert និង Tijen Arin ដោយមានការរួមវិភាគទានពីមិត្តរួមការងារមួយចំនួនធំ) ។ បន្ទាប់ពីមានឯកសារទស្សនាទានកំណត់ត្រាពាក់ព័ន្ធបន្ថែមទៀតស្តីពីសមិទ្ធកម្មរបស់ក្រុមហ៊ុន និងការវិនិយោគផ្ទាល់ពីបរទេស (Asya Akhlaque) អភិបាលកិច្ច (លោក សូ សុខប៊ុនធឿន) ICT (Seda Pahlavooni) ការបង្កើតថ្មី (Smita Kuriakose, Antoine Coste) ជំនាញ (Une Lee, Sanda Liepina) សមត្ថភាពស្ថិតិ (Junhe Yang, Mustafa Dinc)។ ទេសចរណ៍ (Wouters Schalken) ដឹកជញ្ជូន (Genie Jensen) និងនគរូបនីយកម្ម (Judy Baker, Natsuko

Kikutake) ត្រូវបានរៀបចំ។ លើសពីនេះទៀត Theepakorn Jithitikulchai និង Dilaka Lathapipat បានរួមគ្នាសរសេរឯកសារមួយស្តីពីការព្យាករកំណើនរយៈពេលវែង ដែលត្រូវបានរំពឹងថានឹងជាធាតុចូលសម្រាប់ការរៀបចំចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ 2050 នេះ។

អ្នកពិនិត្យរបាយការណ៍នេះរួមមាន Gabriel Demombynes (ប្រធានកម្មវិធី) និង Stephane Guimbert (អ្នកគ្រប់គ្រង) ។

ក្រុមការងារក៏ទទួលបានមតិដ៏មានតម្លៃទៅលើការរកឃើញបឋម និងសារនានានៅក្នុងកិច្ចប្រជុំប្រាំបួនលើក (ប្រព្រឹត្តនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តក្រចេះ)។ សូមអរគុណជាពន្លឹកដល់ភាគីពាក់ព័ន្ធចំនួន 375 នាក់ ដែលបានចូលរួមក្នុងកិច្ចប្រជុំទាំងនោះ និងបានផ្តល់គំនិត និងសំណើរបស់ពួកគេលើដំណើររឿងនេះ និងសំណើអាទិភាព។

ការពិគ្រោះយោបល់និងអន្តរាគមន៍តាមរយៈប័ណ្ណប្រៃសណីយ៍ត្រូវបានរៀបចំដោយសារគំនិត និងការចូលរួមយ៉ាងសកម្មរបស់ក្រុមទំនាក់ទំនងរបស់យើងរួមមាន Leonora Aquino Gonzales លោក ប៊ូ សារឿន លោកស្រី សំអឿន សុភីនិត្យ លោក Ben Alex Manser និង Kanitha Kongrukgreatiyos ព្រមទាំង Elise Vanormelingen (ទីប្រឹក្សា) ។

ជំនួយរដ្ឋបាលដ៏ល្អផ្នែកស្ថាប័ន ត្រូវបានផ្តល់ដោយលោកស្រី ខៀវ អមរា។ ក្រុមការងារនេះក៏សូមថ្លែងនូវកតញ្ញូតាធម៌ចំពោះ លោក លី ច័ន្ទចំរុង (ផ្នែកព័ត៌មានវិទ្យា) ក្រុមរដ្ឋបាល និងគាំទ្រអតិថិជនទាំងមូល រួមមាន លោកស្រី ប៉ុល វណ្ណា លោកស្រី លីន ដា លោកស្រី រ៉ុម ដាណែត លោកស្រី គា គន្ធា អ្នកនាង គង់ លីដែន លោកស្រី ឈុន ឆាយណា លោកស្រី យិន ផល្លា លោកស្រី ជៀប រ៉ាវ៉ាន់ លោកស្រី គី លីនណាផងដែរ ចំពោះការគាំទ្ររបស់ពួកគេក្នុងអំឡុងពេលចូលរួមកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ។

ជាចុងក្រោយ ក្រុមការងារបានទទួលអត្ថប្រយោជន៍ពីការណែនាំ និងការយល់ដឹងរបស់ក្រុមការងារបច្ចេកទេសរបស់សមភាគីរាជរដ្ឋាភិបាលកម្ពុជានៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយ ឯកឧត្តម វង្សី វិសុទ្ធ ឯកឧត្តម ហែម វណ្ណឌី និងលោក ឈាង វណ្ណារិទ្ធ។

| សមាជិកក្រុមការងារវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណ:ជាប្រព័ន្ធ | |
|---|---|
| **ការអនុវត្តន៍ / ប្រធានបទសកល** | **អ្នកទទួលបន្ទុក** |
| កសិកម្ម | ស្ទីវ ចាហ្វី (Steve Jaffee) ចំរើន មុទិតា |
| ការប្រែប្រួលធាតុអាកាស បរិស្ថាននិងធនធានធម្មជាតិ | មីហ្គែល អិនជែល ជចជី (Miguel Angel Jorge) ធីម៉ូធី បូលី (Timothy Bouley) ម៉ាយខិល ម៉ាក់ឃរមិក (Michael McCormick) ធីចិន អារីន (Tijen Arin) ម៉ារៀ ដាំភើត (Maria Dumpert) រ៉ូប៊ើត រ៉េដ (Robert Reid) |
| អប់រំ | បែន ស៊ីមេធ ស៊ូយ៉ូស្ស៊ី ហ្វូកាអូ (Tsuyoshi Fukao) |
| ថាមពល និងនិស្សារណកម្ម | សៀវភីង វ៉ាង (Xiaoping Wang) សូនីល ឃោស្លា (Sunil Khosla) |
| ហិរញ្ញវត្ថុនិងទីផ្សារ | រ៉ាតឆាដា អាណាន់តាវ៉ាស៊ីល្ប៉ា (Ratchada Anantavrasilpa) ខលលីន ម៉ាសេនិក (Colleen Mascenik) |
| យេនឌ័រ និង LGBTI | អេរិក ខលដ៏វែល ចនសាន់ (Erik Caldwell Johnson) ផាមនរ៉ាត យាន់សានហ្គួងវ៉ុង (Pamornrat Tansanguanwong) ធីប៉ាខន ជិតធីគល់ចៃ (Theepakorn Jithitikulchai) អេលីហ្សាវេតា ផេរ៉ូវ៉ា (Elizaveta Perova) ហីលឡារី ចនសាន់ (Hillary Johnson) |
| អភិបាលកិច្ច | លៀ អាព្រីល (Leah April) សូ សុខប៊ុនធឿន |
| សុខភាព អាហារូបត្ថម្ភ និងប្រជាជន | សូមីល ណាក់ផាល (Somil Nagpal) អាន ម៉ារី ប្រូវ៉ូ (Anne Marie Provo) តូម៉ូ ម៉ូរីម៉ូតុ (Tomo Morimoto) |
| សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | ដេនីញែល ស្ទ្រីត (Daniel Street) ដួង សារ៉ាក់ |
| ការបង្កើតថ្មី | ស្មីតា គូរៀខូសេ (Smita Kuriakose) អង់ទាន់ កូស្ត (Antoine Coste) |
| ការងារ និងជំនាញ | ដាលីកា ឡាថាភីផាត (Dilaka Lathapipat) ធីផាកន ជីតធីគុលចៃ (Theepakorn Jithitikulchai) អ៊ូនេ ជី. លី (Une J. Lee) សាន់ដ្រា លីភីណា (Sanda Liepina) |
| ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង សារពើពន្ធ | មីហ្គែល អេដូអាដូ សាន់ឆេស ម៉ារទីន (Miguel Eduardo Sanchez Martin) កាហ្ស៊ី ម៉ាទីន (Kazi Matin) លី សុដេត |
| ភាពក្រីក្រ | អូបើត ភីមហ៊ីដហ្សៃ (Obert Pimhidzai) តុង គីមស៊ុន ខារ៉ូលីណា ម៉ានធីលឡា (Carolina Mantilla) |
| កិច្ចគាំពារសង្គម និងការងារ | ផាប្លូ អាកូស្តា (Pablo Acosta) ខ្លូដៀ ហ្សំប្រា (Claudia Zambra) |
| ភាពធន់ផ្នែកសង្គម ទីក្រុង និង ជនបទ | មីកា ទរហូណេន (Mika Torhonen) ជូឌី បេឃើរ (Judy Baker) ណាតស៊ូកូ គីគូតាកេ (Natsuko Kikutake) ហិនរីខេ ប្រិត្ត (Henrike Brecht) |
| សមត្ថភាពស្ថិតិ | Junhe Yang, Mustafa Dinc |
| ពាណិជ្ជកម្ម និង ភាពប្រកួតប្រជែង | ឡាន វ៉ាន ង្វៀង (Lan Van Nguyen) ហ្គីលើម៉ូ អារ៉េណាស (Guillermo Arenas) វ៉ូធើរ ស្កាល់ខិន(Wouter Schalken) ជច ក្លាក (George Clark) អាស៊ីយ៉ា អាក្លាកេ (Asya Akhlaque) យីហ្វាន វ៉ី (Yifan Wei) វីម ដូវ (Wim Douw) |
| ការដឹកជញ្ជូននិង ICT | សេដា ផាឡាវូនី (Seda Pahlavooni) ហ្សេនី ចិនសិន (Genie Jensen) ប៊ុន វាសនា ណាអូមីហាឡេវូដ (Naomi Halewood) |
| ទឹកស្អាត និងអនាម័យ | ជូប ស្តូតចេសឌីក (Joop Stoutjesdjik) ច័ន្ទ វីរៈ កូវ ភិរម្យ ហ្គ្រិក ប្រៅឌើរ (Greg Browder) |



# និន្នាការរួម

## ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក ប្រទេសកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រយ៉ាងល្អប្រសើរ។

ដោយសារកំណើនសេដ្ឋកិច្ចមានល្បឿនលឿន និងប្រកបដោយចីរភាព កម្ពុជាបានក្លាយទៅជាប្រទេសនាំមុខមួយនៃពិភពលោកក្នុងការកាត់បន្ថយភាពក្រីក្រ និងវិបុលភាពរួម។ ការប៉ាន់ស្មានផ្លូវការនានាបង្ហាញថាភាគរយនៃប្រជាជនកម្ពុជារស់នៅក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិបានធ្លាក់ចុះពី 47,8 ភាគរយ ក្នុងឆ្នាំ 2007 មកត្រឹម 13,5 ភាគរយ ក្នុងឆ្នាំ 2014 ។ ការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើនបានប្រព្រឹត្តទៅជាពិសេសក្នុងអំឡុងឆ្នាំ 2007-2009 ខណៈដែលភាពក្រីក្របានធ្លាក់ចុះ 25 ភាគរយ ហើយប្រជាជនចំនួន 3,3 លាននាក់បានចាកផុតពីភាពក្រីក្រ មួយផ្នែកធំគឺដោយសារការបង្កើនផ្ទៃដីដាំដុះ និងកំណើនតម្លៃម្ហូបអាហារអន្តរជាតិ ដែលផ្តល់អត្ថប្រយោជន៍ដល់កសិករ និងពលករកសិកម្ម។ សូចនាករផ្សេងទៀតនៃកម្រិតជីវភាពរស់នៅដូចជា ការមានទ្រព្យសម្បត្តិរបស់របរប្រើប្រាស់ក្នុងផ្ទះ និងលទ្ធផលនៃការអភិវឌ្ឍធនធានមនុស្សប្រសើរឡើង រួមជាមួយនឹងការសម្រេចបាននូវជោគជ័យរបស់កម្ពុជា លើគោលដៅអភិវឌ្ឍន៍សហសវត្សភាគច្រើនបំផុតនៅឆ្នាំ 2015 (ប្រអប់លេខ 1) ។

កម្ពុជារក្សាអត្រាកំណើនជាមធ្យម 7,6 ភាគរយ ចាប់ពីឆ្នាំ 1994 ដល់ឆ្នាំ 2015 ជាប់ចំណាត់ថ្នាក់ទីប្រាំមួយនៅលើពិភពលោក ហើយសព្វថ្ងៃបានក្លាយជាប្រទេសមួយដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ កំណើនត្រូវបានជំរុញដោយការនាំចេញទំនិញនិងសេវាកម្ម (ជាចម្បងគឺសម្លៀកបំពាក់ និងទេសចរណ៍) មានកំណើនជាខ្លាំង ក្នុងកម្រិត 19,6 ភាគរយ ក្នុងមួយឆ្នាំ ដែលកម្ពុជាជាប់លំដាប់ទីពីរនៅលើពិភពលោកបន្ទាប់ពីប្រទេសហ្គីណេអេក្វាទ័រ និងនាំមុខប្រទេសដែលមានកំណើនខ្ពស់ ដូចជា ប្រទេសវៀតណាម និងបង់ក្លាដែស ជាដើម។ វិស័យកសិកម្ម វិស័យសំណង់ និងអចលនទ្រព្យ កាលពីពេលថ្មីៗនេះក៏ជាក្បាលម៉ាស៊ីនចម្បងនៃកំណើនសេដ្ឋកិច្ចរឹងមាំផងដែរ។ ជាលទ្ធផល ចំណូលជាតិសរុប (GNI) ក្នុងពលរដ្ឋម្នាក់ៗបានកើនឡើងជាងបីដង ពី 300 ដុល្លារអាមេរិក ក្នុងឆ្នាំ 1994 ដល់ 1.070 ដុល្លារអាមេរិក ក្នុងឆ្នាំ 2015 ដែលជាឆ្នាំកម្ពុជាបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ សមិទ្ធិផលដ៏គួរឱ្យចាប់អារម្មណ៍របស់កម្ពុជាត្រូវបានកសាង លើមូលដ្ឋាននៃការបើកចំហពាណិជ្ជកម្ម និងលំហូរមូលធនដែលជំរុញដោយភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម និងលំហូរចូលយ៉ាងច្រើននៃជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) និងវិនិយោគផ្ទាល់ពីបរទេស (FDI) ។

### ការរកឃើញសំខាន់ៗ

“ការងារ ប្រមាណជា 3,6 លាន ក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មត្រូវបានបង្កើតឡើងក្នុងរយៈកាលពីរទសវត្សរ៍កន្លងទៅ”

## ប្រអប់លេខ 1: វឌ្ឍនភាពរបស់កម្ពុជាឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍

ជាទូទៅ កម្ពុជាមានវឌ្ឍនភាពយ៉ាងច្រើនក្នុងការសំរេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)។ ឧទាហរណ៍ ភាពក្រីក្រធ្ងន់ធ្ងរបានកាត់បន្ថយច្រើនជាងពាក់កណ្តាល (ពី 33 ភាគរយ ក្នុងឆ្នាំ 2004 មកត្រឹម 10 ភាគរយ នៅឆ្នាំ 2011) អត្រាមរណភាពមាតាបានកាត់បន្ថយច្រើនជាងពាក់កណ្តាល (ពីកំណើតរស់ 1.020 នាក់ ក្នុងឆ្នាំ 1990 មកត្រឹម 161 នាក់ក្នុងឆ្នាំ 2015 ក្នុងកំណើតរស់ 100.000 នាក់) អត្រាមរណភាពកុមារ បានកាត់បន្ថយ (ពី 117 ក្នុង 1.000 នាក់ក្នុងឆ្នាំ 1990 មកត្រឹម 28 នាក់ ក្នុងឆ្នាំ 2015) អត្រាចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សាបានបង្កើន (ពី 92,1 ភាគរយក្នុងឆ្នាំ 2000ដល់អត្រាចុះឈ្មោះចូលរៀនជិតស្មើកម្រិតសកល ចំនួន 94,7 ភាគរយ ក្នុងឆ្នាំ 2014) និង មានវឌ្ឍនភាពជាខ្លាំងផងដែរក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ / ជំងឺអេដស៍ (ជាមួយនឹងការធ្លាក់ចុះនៃអត្រាកើតរោគនេះពី 0,08 ក្នុងចំនួនប្រជាជន 100 នាក់ក្នុងឆ្នាំ 2001 មកត្រឹម 0,01 ក្នុងឆ្នាំ 2013) ។

ទោះយ៉ាងណាក្តី សមិទ្ធិផលសម្រាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍មួយចំនួនមានលក្ខណៈចម្រុះ ក្នុងនោះរួមមានជំងឺរបេង និរន្តរភាពបរិស្ថាន ការដោះមីន និងសមភាពយេនឌ័រ។ អត្រាកើតជំងឺរបេង និងអត្រាស្លាប់ដោយសាររបេងនៅតែមានកម្រិតខ្ពស់។ ទោះបីជាល្បឿននៃការបំផ្លាញព្រៃឈើបានថយចុះបន្តិច ដោយសារការផ្លាស់ប្តូរគោលនយោបាយកាលពីពេលថ្មីៗកន្លងទៅក្តី ការកាប់បំផ្លាញនៅតែមានកម្រិតខ្ពស់ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក។ ដូចគ្នានេះដែរ ទោះបីភាគរយនៃដីដែលមានយុទ្ធភណ្ឌមិនទាន់ផ្ទុះត្រូវបានបោសសម្អាត បានកើនឡើងដល់ 45ភាគរយក្តី ការបោសសម្អាតនេះនៅតែខុសឆ្ងាយពីគោលដៅនៃការបោសសម្អាតចំនួន 100ភាគរយនៅឡើយ។



ក្នុងទ្រង់ទ្រាយធំ ជោគជ័យរបស់ប្រទេសកម្ពុជាអាស្រ័យលើការបង្កើតការងារ។ ជាមួយនឹងការកើនឡើងនូវចំនួនប្រជាជនដែលស្ថិតក្នុងវ័យធ្វើការ កម្ពុជាកំពុងតែស្ថិតក្នុង "ដំណាក់កាលដំបូងនៃភាគលាភប្រជាសាស្ត្រ" របស់ខ្លួននៅឡើយ ហើយកន្លងមក ទទួលបានជោគជ័យជាខ្លាំង ក្នុងការបង្កើតការងារសម្រាប់យុវជន និងស្ត្រីក្នុងសកម្មភាពអតិពលកម្មនានា។ កម្ពុជាបានទទួលអត្ថប្រយោជន៍ពីបំលែងរចនាសម្ព័ន្ធទ្រង់ទ្រាយធំ មានន័យថា ការបែងចែកសារឡើងវិញនូវសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យទាំងបីនៃវិស័យកសិកម្ម កម្មន្តសាល និងសេវាកម្ម បានបង្កើតឱកាសការងារសុទ្ធចំនួនប្រមាណជា 3,6 លាន ក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម និង 0,7 លាននាក់ក្នុងវិស័យកសិកម្ម និងជលផលក្នុងរយៈកាលពីរទសវត្សរ៍កន្លងទៅ។

កំណើនសេដ្ឋកិច្ចក៏ត្រូវបានជំរុញដោយសម្បត្តិធម្មជាតិស្តុកស្តម្ភ និងសម្បូរបែបរបស់ប្រទេសកម្ពុជាដែលទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជារាប់លាននាក់ផងដែរ។ កសិកម្មដែលពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិ និងសេវាប្រព័ន្ធអេកូឡូស៊ី បានរួមចំណែក 30 ភាគរយនៃផសស (GDP) ក្នុងឆ្នាំ 2015។ ប្រជាជនជាងប្រាំលាននាក់ពឹងផ្អែកលើវិស័យកសិកម្ម និងនេសាទ ដើម្បីរកចំណូលបន្ថែម និងទ្រទ្រង់សន្តិសុខស្បៀងរបស់ពួកគេ ហើយ 88 ភាគរយនៃចំនួនប្រជាជននៅពឹងផ្អែកលើជីវម៉ាស់ប្រពៃណីសម្រាប់ការចម្អិនអាហារ។ វិស័យទេសចរណ៍ជាក្បាលម៉ាស៊ីនមួយផ្សេងទៀតនៃកំណើនសេដ្ឋកិច្ច ក៏ពឹងផ្អែកលើធនធានធម្មជាតិ និងនិរន្តរភាពបរិស្ថានផងដែរ។

## ក្នុងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងបញ្ហាប្រឈមថ្មីៗក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចឱ្យរឹងមាំ។

តទៅអនាគត កម្ពុជាទំនងជាមិនអាចពឹងផ្អែកលើកត្តាដដែល ដែលបានជំរុញឱ្យមានកំណើនរឹងមាំ និងការកាត់បន្ថយភាពក្រីក្រដូចក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកបានឡើយ។ ការបញ្ចប់ជាយថាហេតុរបស់កម្ពុជាពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) នឹងធ្វើឱ្យការផ្តល់ហិរញ្ញប្បទានពីម្ចាស់ជំនួយ និងភាពអនុគ្រោះពាណិជ្ជកម្មធ្លាក់ចុះ និងបាត់បង់យ៉ាងច្រើន។ ទន្ទឹមនឹងនេះ ប្រាក់ខែកំពុងកើនឡើង ហើយវានឹងធ្វើឱ្យប្រទេសកម្ពុជាជួបការលំបាកកាន់តែខ្លាំងក្នុងការនាំចេញស្រូវអង្ករមិនទាន់កែច្នៃ និងសម្លៀកបំពាក់ដែលមានតម្លៃថោក។ នៅក្នុងករណីនៃវិស័យកសិកម្ម ទស្សនវិស័យលើថ្លៃទំនិញពុំមានលក្ខណៈវិជ្ជមានឡើយរីឯវិសាលភាពរបស់ប្រទេសកម្ពុជាក្នុងការពង្រីកផ្ទៃដីដាំដុះសព្វថ្ងៃក៏កាន់តែតិច ជាពិសេសបើគេគិតដល់តម្រូវការសម្រាប់ឱ្យមាននិរន្តរភាពបរិស្ថាន។

គួរឱ្យកត់សំគាល់ដែរថាផលិតភាពនៃការងារបានកើនឡើងយឺតជាងប្រទេសកំពុងលូតលាស់ខ្លាំងផ្សេងទៀត មួយផ្នែកគឺដោយសារតែការប្រើប្រាស់មូលធនតិចតួចនៅក្នុងផលិតកម្ម។ ក្នុងអំឡុង 1993-2014 ប្រទេសកម្ពុជាមានកំណើនផលិតភាពការងារ 3,5 ភាគរយ ធៀបនឹង 4,7 ភាគរយនៅវៀតណាមក្នុងអំឡុងដូចគ្នា និងអត្រាកំណើនជាមធ្យម 7,1 ភាគរយ នៅប្រទេសថៃក្នុងអំឡុងឆ្នាំមានសន្ទុះរីកចម្រើន ចាប់ពីឆ្នាំ 1986 ដល់ 1996 (រូបភាពទី 1, ខាងឆ្វេង) ។

រូបលេខ 1. ផលិតភាពពលកម្មមានកំណើនទាបជាងគូប្រជែង (ខាងឆ្វេង) មួយផ្នែកគឺ ដោយសារឯកទេសភាវូបនីយកម្មលើឧស្សាហកម្មដែលប្រើទុនតិច(ខាងស្តាំ)




*ប្រភព: ការគណនារបស់បុគ្គលិកធនាគារពិភពលោកដោយប្រើប្រាស់គណនីជាតិនិង WDI ។*
*ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោកផ្អែកលើអង្កេតសហគ្រាសឆ្នាំ 2016 ។*

ផលិតភាពនៅក្នុងឧស្សាហកម្មកាត់ដេរនៅតែទាបជាងប្រទេសគូប្រជែងភាគច្រើន ហើយមានភស្តុតាងបង្ហាញថាការវិនិយោគមានទំហំតិចតួចលើការកែលម្អបរិក្ខារ និងគ្រឿងចក្រ (រូបភាពលេខ 1 ខាងស្តាំ) ។ ការបង្កើតទុនដុលសរុបជាភាគរយនៃ ផសស ជាមធ្យម តិចជាង 20 ភាគរយនៃ ផសស ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក មានកម្រិតទាបជាងប្រទេសគូប្រជែង ហើយទាបជាងប្រទេសវៀតណាម និងប្រទេសថៃជាខ្លាំងក្នុងអំឡុងឆ្នាំដែលមានសន្ទុះរីកចម្រើនខ្ពស់។

នៅចំពោះមុខការធ្លាក់ចុះនៃភាពប្រកួតប្រជែង ផលិតកម្មដែលមានតម្លៃថោករបស់កម្ពុជា និងការប្រមូលផ្តុំជាខ្លាំងលើវិស័យកាត់ដេរ និងទេសចរណ៍ នឹងក្លាយជាបញ្ហាប្រឈមកាន់តែខ្លាំងឡើង។ មុខទំនិញភាគច្រើននៃការនាំចេញសម្លៀកបំពាក់របស់កម្ពុជា មានគោលដៅផ្តោតលើប្រភេទសម្លៀកបំពាក់ដែលមានគុណភាពទាប/តម្លៃថោក នៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ ទើបតែក្នុងកំឡុងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុណ្ណោះ ដែលរោងចក្រកាត់ដេរសម្លៀកបំពាក់មួយចំនួនបានចាប់ផ្តើមប្តូរទៅធ្វើការងារដែលផ្តល់តម្លៃបន្ថែមខ្ពស់ (ប៉ាក់ បោកគក់ បោះពុម្ព) ទំនងជាដោយសារការធ្លាក់ចុះនៃភាពប្រកួតប្រជែងនៅបរទេសក្នុងបរិបទនៃប្រាក់ដុល្លារអាមេរិកថ្លៃ និងការតម្លើងប្រាក់ឈ្នួលអប្បបរមាយ៉ាងឆាប់រហ័ស (ពី 80 ដុល្លារអាមេរិក ក្នុងមួយខែ ក្នុងឆ្នាំ 2013 ទៅ 153 ដុល្លារ ក្នុងមួយខែ ក្នុងឆ្នាំ 2017 ដែលឥឡូវនេះប្រហាក់ប្រហែលនឹងប្រទេសវៀតណាម)។ ខណៈដែលផលិតផលនាំចេញមានតម្លៃខ្ពស់មួយចំនួន (រួមទាំង កង់ គ្រឿងបន្លាស់ទូរទស្សន៍ និងខ្សែបញ្ជេះ) ត្រូវបានសង្កេតឃើញក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ សកម្មភាពភាគ

ច្រើនទាំងនេះនៅក្នុងប្រទេសកម្ពុជា នៅតែជាសកម្មភាពតម្លើងដែលប្រើកម្លាំងពលកម្មច្រើន ដោយគ្មាន ឬមានការផលិតបំណែក និងគ្រឿងបន្លាស់តិចតួចប៉ុណ្ណោះ។ វិស័យទេសចរណ៍ក៏ប្រឈមនឹងតាមការឡើងថ្លៃប្រាក់ដុល្លារអាមេរិក និងការតម្លើងប្រាក់ឈ្នួលដែរ ហើយបញ្ហាប្រឈមផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងនិរន្តរភាពបរិស្ថាន ធ្វើឱ្យការធ្វើពិពិធកម្មនៃសកម្មភាពនានាក្នុងវិស័យនេះជួបការលំបាក។

ឧបសគ្គផ្នែកស្ថាប័ន មូលធនមនុស្ស និង ហេដ្ឋារចនាសម្ព័ន្ធ ធ្វើឱ្យរាំងស្ទះដល់ភាពប្រកួតប្រជែង ក៏ដូចជារាំងស្ទះដល់ការបង្កើតវិស័យឯកជនមួយរស់រវើកនៅកម្ពុជា។ ថ្វីបើមានការរីកចម្រើនមួយចំនួនក្តី កម្ពុជាដើរយឺតជាងប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបដទៃទៀតលើផ្នែកទាំងនេះ (រូបភាពលេខ 2)។ ភាពស្មុកស្មាញនៃដំណើរការទម្រង់នីយកម្ម ធ្វើឱ្យកម្ពុជាក្លាយជាកន្លែងមួយលំបាកបំផុតក្នុងការចុះបញ្ជីអាជីវកម្ម ពោលគឺកម្ពុជាស្ថិតក្នុងលំដាប់ទី 180 ក្នុងចំណោមប្រទេសចំនួន 189 នៅលើទិដ្ឋភាពនេះ ដោយត្រូវចំណាយពេល 87 ថ្ងៃ មុននឹងអាចចាប់ផ្តើមអាជីវកម្មណាមួយ (ធៀបនឹង 25,9 ថ្ងៃនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក)។ ការទទួលបានការអប់រំតិចតួចក៏រាំងស្ទះដល់ការធ្វើពិពិធកម្ម និងការធ្វើឱ្យសេដ្ឋកិច្ចប្រសើរឡើងផងដែរ ទោះបីជាការចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតបឋមសិក្សាបានកើនឡើងយ៉ាងខ្ពស់ក្តី អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ (43 ភាគរយ ក្នុងឆ្នាំ 2013) នៅតែស្ថិតក្រោមមធ្យមភាគសម្រាប់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (71 ភាគរយ)។ សហគ្រិនបានឱ្យដឹងថាវិញ្ញាបនបត្រ និងសញ្ញាបត្រពីសាលារៀន ទោះជានៅកម្រិតឧត្តមសិក្សាក្តី ពុំមែនជាសញ្ញាបង្ហាញសមត្ថភាពរបស់កម្មករឡើយ ដែលចំណុចនេះសឱ្យឃើញនូវបញ្ហាផ្នែកគុណភាព។ លើសពីនេះទៀត ការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ប្រឈមមុខនឹង

## ការរកឃើញសំខាន់ៗ

"កម្ពុជាស្ថិតក្នុងលំដាប់ទី 180 ក្នុងចំណោមប្រទេសចំនួន 189 ដោយត្រូវចំណាយពេល 87 ថ្ងៃ មុននឹងអាចចាប់ផ្តើមអាជីវកម្មណាមួយ"

រូបលេខ 2. កម្ពុជានៅមានភាពយឺតយ៉ាវនៅឡើយលើទិដ្ឋភាពមួយចំនួននៃភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច




*ប្រភព: Global Competitiveness Indicators, World Economic Forum.*

## ការរកឃើញសំខាន់ៗ

“សិស្សថ្នាក់ទី 6 ចំនួន 39% មានពិន្ទុទាបចំពោះសមត្ថភាពអានភាសាខ្មែរកម្រិតបឋម និង ប្រមាណជាមួយភាគបីនៃកុមារអាយុក្រោម 5 ឆ្នាំជាកុមារក្រិន”

ទស្សនៈអវិជ្ជមាន ហើយហាក់ដូចជាមិនផ្តល់នូវជំនាញដែលវិស័យឯកជនកំពុងត្រូវការទេ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធវិញ មានការរីកចំរើនច្រើនក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប៉ុន្តែតម្លៃអគ្គិសនីនៅតែខ្ពស់បើប្រៀបធៀបទៅនឹងប្រទេសជិតខាង៖ ថ្លៃថាមពលអគ្គិសនីមធ្យមសម្រាប់អ្នកប្រើប្រាស់ផ្នែកឧស្សាហកម្មធំៗយ៉ាងហោចណាស់នៅខ្ពស់ជាងប្រទេសថៃ មីយ៉ាន់ម៉ា ឬវៀតណាមយ៉ាងតិច 35 ភាគរយ។

### ដើម្បីធានាថាកំណើនសេដ្ឋកិច្ចនឹងបន្តមានលក្ខណៈបរិយាប័ន្ន គប្បីជំនះឧបសគ្គទាំងឡាយណាដែលប៉ះពាល់ជាពិសេសដល់គ្រួសារក្រីក្រ។

មូលធនមនុស្សមានកម្រិតប៉ះពាល់ដល់ចលភាពសេដ្ឋកិច្ចសង្គមកិច្ច។ តាមស្តង់ដារអន្តរជាតិប្រជាពលរដ្ឋកម្ពុជាភាគច្រើនដែលមិនស្ថិតក្នុងភាពក្រីក្រខ្លាំង គឺជាប្រជាជនក្រីក្រមធ្យម ឬងាយរងគ្រោះក្នុងការធ្លាក់ចូលក្នុងភាពក្រីក្រ មានចំនួនពីរភាគបីរស់នៅដោយមានសមភាពអំណាចទិញ (PPP)ទាបជាង 5,50 ដុល្លារអាមេរិក ក្នុងមួយថ្ងៃ ។ កំណើនយឺតនៃក្រុមអ្នកមានសុវត្ថិភាពផ្នែកសេដ្ឋកិច្ច អាចបណ្តាលមកពីទាយជ្ជទានគ្រួសារមានកម្រិតទាបលើផ្នែកអប់រំ សុខាភិបាល និងដីធ្លី។ ការវាយតម្លៃថ្នាក់ជាតិអំពីសមិទ្ធិផលរបស់សិស្សបានរកឃើញថា សិស្សថ្នាក់ទី 6 ចំនួន 39% មានពិន្ទុទាបចំពោះសមត្ថភាពអានភាសាខ្មែរកម្រិតបឋម។ លទ្ធផលនៃការរៀនសូត្រមិនល្អបែបនេះ អាចបណ្តាលមកពីគ្រូដែលទទួលបានការបណ្តុះបណ្តាល មានចំនួនតិច ទទួលបានការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ ម៉ោងសិក្សាមានចំនួនតិចជាងមិត្តភក្តិរបស់ខ្លួនដែលទាំងអស់នេះ ធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់សិស្សម្នាក់ៗក្នុងការលើកកម្រិតសេដ្ឋកិច្ចសង្គម។

កំហិតនៃមូលធនមនុស្សចាប់ផ្តើមកាលគ្រាដំបូង នៃជីវិតដោយសារគ្មានអាហាររូបត្ថម្ភគ្រប់គ្រាន់ ខ្វះការថែទាំ និងគ្មានការជម្រុញទឹកចិត្តពីដើមទី។ ដោយបានចម្រើនធំពេញវ័យក្នុងអំឡុងពេលដែលមានភាពក្រីក្រជាខ្លាំង និងកង្វះអាហាររូបត្ថម្ភរបស់មាតា និងកុមារ ក្រុមយុវពលករបច្ចុប្បន្នរបស់កម្ពុជាភាគច្រើនទំនងជាទទួលរងនូវផលវិបាកអវិជ្ជមានយូរអង្វែង ពីកង្វះអាហាររូបត្ថម្ភកាលពីកុមារភាព និងភាពខ្វះសព្វខ្វះគ្រប់ផ្សេងទៀតកាលនៅតូច។ ប្រមាណជា 33 ភាគរយនៃកុមារអាយុក្រោម 5 ឆ្នាំជាកុមារក្រិន (រូបលេខ 3 ខាងឆ្វេង) ហើយមានតែ 35,9 ភាគរយនៃក្មេងអាយុ 3-5 ឆ្នាំប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀនក្នុងអំឡុងឆ្នាំសិក្សា 2014-15។ ការទទួលបានទឹកស្អាត និងបង្គន់អនាម័យ (75 ភាគរយ និង 42 ភាគរយ រៀងគ្នានៃចំនួនប្រជាជនសរុប) នៅតែមានកម្រិតទាបជាងជាខ្លាំងធៀបនឹងមធ្យមភាគនៃប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (90 ភាគរយ និង 52 ភាគរយ រៀងគ្នា រូបលេខ 3 ខាងស្តាំ) និងជាកត្តាដ៏សំខាន់មួយចំពោះភាពក្រិន ទន្ទឹមនឹងការផ្តល់អាហារដល់ទារកមិនបានល្អ និង ភាពអត្តខាត់នៃចំណីអាហារ។ លើសពីនេះ ទោះបីជាមានភាពប្រសើរឡើងច្រើនក្តី ក៏កម្ពុជានៅតែមានអត្រាមរណភាពមាតាខ្ពស់ជាងគេនៅក្នុងតំបន់ (161 ក្នុងចំណោមកំណើតរស់ 100.000 នាក់ ក្នុងឆ្នាំ 2015) ដែលបង្ហាញនូវបញ្ហាលើគុណភាពក្នុងការថែទាំ និងទទួលបានសេវាសុខភាព ។

រូបលេខ 3. អត្រាប្រេវ៉ាឡង់ជម្ងឺក្រិនមានកម្រិតខ្ពស់ក្នុងចំណោមអ្នកក្រ (ខាងឆ្វេង) ហើយកម្ពុជាដើរមិនទាន់ប្រទេសដទៃទៀតក្នុងការទទួលបានទឹកស្អាត និងសេវាអនាម័យ (ខាងស្តាំ)




*ប្រភព: UNICEF (ឆ្វេង); WHO/UNICEF Joint Monitoring Program (ស្តាំ)*

## ការរកឃើញសំខាន់ៗ

"ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសចំនួន 10 លើពិភពលោក ក្នុងការចំណាយប្រាក់ហោប៉ៅលើផ្នែកសុខភាព ស្មើនឹង 60 ភាគរយ នៃថ្លៃចំណាយសុខភាពសរុប។"

ចលភាពសេដ្ឋកិច្ចសង្គមកិច្ចក៏ត្រូវបានរារាំងដោយការប្រឈមមុខខ្ពស់ទៅនឹងវិបត្តិហិរញ្ញវត្ថុ និងអាកាសធាតុ ដែលមានការគាំពារសង្គមតិចតួចបំផុតក្នុងការជួយគ្រួសារលើការគ្រប់គ្រងវិបត្តិនានា។ ប្រជាជនប្រមាណជា 6,3 ភាគរយនៃចំនួនប្រជាជនសរុបបានចំណាយយ៉ាងច្រើនក្នុងឆ្នាំ 2013 ហើយ 3,1 ភាគរយ ជាប់បំណុលគេក្នុងការទូទាត់លើចំណាយសុខភាព។ ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសចំនួន 10 លើពិភពលោក ក្នុងការចំណាយប្រាក់ហោប៉ៅលើផ្នែកសុខភាព ដោយត្រូវចំណាយប្រាក់ហោប៉ៅលើសេវាសុខភាពស្មើនឹង 60 ភាគរយ នៃថ្លៃចំណាយសុខភាពសរុប។ ផ្អែកលើសន្ទស្សន៍ហានិភ័យពិភពលោករបស់អង្គការសហប្រជាជាតិ (រូបភាពទី 4) គ្រោះមហន្តរាយគឺជាប្រភពមួយទៀតនៃការចំណាយដ៏សន្ធឹកសន្ធាប់ ដោយប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់លេខ 8 ជាប្រទេសដែលងាយរងគ្រោះបំផុតចំពោះគ្រោះមហន្តរាយនៅលើពិភពលោកក្នុងឆ្នាំ 2015 ។ ការប៉ាន់ស្មានតម្រូវការក្រោយទឹកជំនន់ឆ្នាំ 2013 បានរកឃើញថាប្រាក់ចំណូលមធ្យមប្រចាំខែរបស់អ្នករងផលប៉ះពាល់បានធ្លាក់ចុះច្រើនជាង 25 ភាគរយ ស្មើនឹង 37,6 លានដុល្លារអាមេរិក។ ទន្ទឹមនឹងនេះ ប្រព័ន្ធគាំពារសង្គមកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ដោយកម្ពុជាចំណាយតិចជាង 0,1 ភាគរយនៃ ផសស លើជំនួយសង្គមធៀបនឹងមធ្យមភាគពិភពលោក 1,6 ភាគរយ[1]។

1 ASPIRE database. Accessible at datatopics.worldbank.org/aspire/.

រូបលេខ 4. ប្រៀបធៀបជាមួយប្រទេសដទៃ ប្រទេសកម្ពុជាប្រឈមមុខ និងមានភាពងាយរងគ្រោះខ្ពស់ជាខ្លាំងចំពោះគ្រោះមហន្តរាយនានា

សន្ទស្សន៍ហានិភ័យពិភពលោកប្រទេស ប្រឈមមុខបំផុតចំនួន20




*ប្រភព: United Nations University (2015)*

គម្លាតផ្នែកយេនឌ័រដែលតែងកើតមានលើប្រាក់ចំណូល និងគុណភាពការងារ ក៏ចោទជាបញ្ហាប្រឈមមួយក្នុងការសំរេចបាននូវវិបុលភាពរួមគ្នាផងដែរ។ ការចូលរួមជាកម្លាំងពលកម្មរបស់ស្ត្រីនៅប្រទេសកម្ពុជាស្មើនឹង 79 ភាគរយ ក្នុងឆ្នាំ 2014 ជាការចូលរួម ដែលមានអត្រាខ្ពស់បំផុតនៅលើពិភពលោក ហើយសហគ្រាសដែលជាកម្មសិទ្ធិរបស់ស្ត្រីមានជាងពាក់កណ្តាលនៃគ្រឹះស្ថានអាជីវកម្មទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយអាជីវកម្មដែលជាកម្មសិទ្ធិរបស់ស្ត្រី ជាទូទៅ មានទំហំតូច ចំណេញតិចជាង ហើយទំនងជាចុះបញ្ជីតិចជាងអាជីវកម្មរបស់បុរស។ ខណៈដែលស្ត្រីតំណាងឱ្យ 85% នៃកម្លាំងពលកម្មក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្ត្រីភាគច្រើនធ្វើការផ្នែកតម្លើង ចំណែកឯការងារដែលមានគុណភាព មានប្រាក់ឈ្នួលខ្ពស់ និងការត្រួតពិនិត្យ បុរសជាអ្នកធ្វើ។ ជាងនេះទៅទៀត យោងតាមអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ 2014 គម្លាតប្រាក់ចំណូលយេនឌ័រនៅឆ្នាំ 2014 មានកម្រិតស្មើនឹង 30% ក្នុងចំណោមអ្នកដែលមានការអប់រំកម្រិតទាប ជាពិសេស ធ្លាក់ចុះដល់ 7% ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ដែលបង្ហាញឱ្យឃើញសារៈសំខាន់នៃការលុបបំបាត់គម្លាតក្នុងការទទួលបានការអប់រំ។ ចំពោះភាពតំណាងផ្នែកនយោបាយ ស្ត្រីមានចំនួនត្រឹមតែ 7% នៃតំណែងរដ្ឋមន្ត្រី ធ្វើឱ្យកម្ពុជាស្ថិតក្នុងបណ្តាប្រទេសលំដាប់ក្រោមគេបំផុត 20% នៅលើពិភពលោក (Union Inter Parliamentary សម្ព័ន្ធអន្តរសភា2016) ។

ការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល បានគូសបញ្ជាក់ថាក្រុមប្រជាពលរដ្ឋខ្លះនៅតែជួបប្រទះនឹងការមិនយកចិត្តទុកដាក់ និងការផាត់ចេញពីសង្គម ដែលបង្កើនឡើងនូវភាពងាយរងគ្រោះរបស់ពួកគេ ហើយរារាំងពួកគេពីការទទួលបានផលប្រយោជន៍នៃកំណើនសេដ្ឋកិច្ច។ ឧទាហរណ៍ ប្រមាណ 10 ភាគរយ នៃប្រជាជនកម្ពុជា យ៉ាងហោចណាស់រងគ្រោះពីទម្រង់មួយនៃពិការភាព។ ប្រមាណ 45 ភាគរយនៃមនុស្សពេញវ័យដែលមានពិការភាពគ្មានប្រាក់ចំណូល ហើយជនពិការមានទ្រព្យសម្បត្តិ ប្រហែលពាក់កណ្តាលនៃអ្នកមិនពិការ។ ស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ភេទទាំងពីរ ខ្ទើយ និង / ឬអ្នកមានភេទមិនច្បាស់លាស់ (LGBTI) បន្តប្រឈមមុខនឹងការមាក់ងាយពីសំណាក់ក្រុមគ្រួសារ សហគមន៍របស់ពួកគេ ពីប្រព័ន្ធផ្សព្វផ្សាយ និងការរើសអើងនៅកន្លែងធ្វើការងារ និងនៅសាលារៀន។ ទោះបីជនជាតិភាគតិចពុំមានអត្រាភាពក្រីក្រខ្ពស់ច្រើនជាងមធ្យមភាគក្តី ពួកគេងាយរងគ្រោះជាខ្លាំងចំពោះការបាត់បង់ដីធ្លី។ ក្នុងឆ្នាំ 2007 មានការប៉ាន់ប្រមាណថាសហគមន៍ជនជាតិដើមភាគតិចបានបាត់បង់ដីប្រពៃណីរបស់ពួកគេ 30 ភាគរយ ចាប់តាំងពីឆ្នាំ 1989 មក ហើយជម្លោះដីធ្លីនៅតែជាបញ្ហាចម្រូងចម្រាសយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។

កន្លងមក ខណៈមិនរាំងស្ទះដល់កំណើន និងការកាត់បន្ថយភាពក្រីក្រខ្លាំងក្លាក្តី បញ្ហាប្រឈមផ្នែកអភិបាលកិច្ចធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់ក្រុមហ៊ុន ប៉ះពាល់ដល់គុណភាពនៃការផ្តល់សេវាសាធារណៈ និងការទទួលបានទ្រព្យសម្បត្តិ និងឱកាសនានា។ អត្រាអំពើសូកប៉ាន់ (ប៉ះពាល់ដល់ក្រុមហ៊ុនចំនួន 63 ភាគរយ នៃចំនួនក្រុមហ៊ុនរាយការណ៍ក្នុងឆ្នាំ 2016) បានធ្លាក់ចុះបន្តិច ប៉ុន្តែកន្លងមកនៅតែខ្ពស់ជាងគេបំផុតក្នុងចំណោមបណ្តាប្រទេសដែលមានលក្ខណៈស្រដៀងគ្នា។ នៅក្នុងសន្ទស្សន៍ទស្សនៈស្តីពីអំពើពុករលួយឆ្នាំ 2015 ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី 150 ដោយមានតែអាហ្គានីស្ថាននិងកូរ៉េខាងជើងប៉ុណ្ណោះដែលបានអនុវត្តអន់ជាងកម្ពុជានៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល និងអប់រំនៅតែទាបជាងមធ្យមភាគសម្រាប់សេដ្ឋកិច្ចដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយនៅតែពឹងផ្អែកជាខ្លាំងលើម្ចាស់ជំនួយក្នុងការផ្តល់សេវាសាធារណៈ។ ខណៈសម្រេចបានវឌ្ឍនភាពយ៉ាងច្រើនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ឧទាហរណ៍ គណនីរតនាគារទោល ការអនុវត្តន៍ថវិកាកម្មវិធី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ) ចំណុចខ្សោយជាមូលដ្ឋាននៅតែមានវត្តមាន (រដ្ឋាភិបាល 2015a)។ បរិបាលកិច្ច ការបែងចែកធនធានមនុស្សមិនបានត្រឹមត្រូវ និងសមត្ថភាពមានកម្រិត នៅក្នុងកិច្ចការសាធារណៈនៅតែជាបញ្ហា។ ជាចុងក្រោយ ក្នុងបរិបទនៃការអនុវត្តនីតិរដ្ឋមិនបានល្អ វិវាទដីធ្លីនិងការបណ្តេញចេញ បានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះជាខ្លាំង ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល 15 ឆ្នាំក្តី។

## ហានិភ័យបណ្តាលមកពីកំណើនឥណទានឆាប់រហ័ស និងការរិចរិលធនធានធម្មជាតិ អាចប៉ះពាល់ដល់និរន្តរភាពសេដ្ឋកិច្ច។

ហានិភ័យមួយចំនួនដែលកំពុងតែលេចឡើងអាចប៉ះពាល់ដល់លំអានអភិវឌ្ឍរបស់កម្ពុជា រួមមានការបង្កើនការប៉ះពាល់ដល់បំណុលមីក្រូហិរញ្ញវត្ថុ និងការឡើងកំដៅហិរញ្ញវត្ថុ។ខណៈកម្ពុជា

## ការរកឃើញសំខាន់ៗ

"គម្លាតប្រាក់ចំណូលយេនឌ័រនៅឆ្នាំ 2014 មានកម្រិតស្មើនឹង 30% ក្នុងចំណោមអ្នកដែលមានការអប់រំកម្រិតទាប ជាពិសេសធ្លាក់ចុះដល់ 7% ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ"

មានហានិភ័យទាបនៃបំណុល (IMF 2016) កម្មវិធីបង្កើនប្រាក់ខែបួនដងក្នុងវិស័យសាធារណៈ (ចន្លោះឆ្នាំ 2013 និងឆ្នាំ 2018) កំពុងបង្កើនសម្ពាធសារពើពន្ធ ដោយហេតុថាបញ្ជីប្រាក់ខែសាធារណៈមានទំហំ ប្រមាណជា 40ភាគរយនៃចំណូលជាតិរួចទៅហើយ។ ចំពោះហានិភ័យម៉ាក្រូហិរញ្ញវត្ថុវិញ ការផ្តល់ឥណទានរបស់កម្ពុជាទៅវិស័យឯកជនកំពុងមានសន្ទុះខ្លាំងក្លា និងកើនឡើងពី 2 ភាគរយនៃ ផសស ក្នុងឆ្នាំ 1993 ដល់ 63 ភាគរយនៅក្នុងឆ្នាំ 2015 ខ្ពស់ជាងកម្រិតមធ្យមសម្រាប់ប្រទេសមានចំណូលមធ្យមកម្រិតទាប (រូបភាពលេខ 5 ខាងឆ្វេង) ។ ឥណទាននៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) កំពុងមានសន្ទុះជាខ្លាំងផងដែរ គឺកើនឡើងជាង 40 ភាគរយនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅទំហំប្រាក់កម្ចីជាមធ្យមបានកើនឡើងប្រមាណជា 200 ដុល្លារអាមេរិកទៅ 1000 ដុល្លារអាមេរិក ស្មើនឹងពីរដងនៃកំណើនប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗពីឆ្នាំ 2004-14 (រូបភាពលេខ 5 ខាងស្តាំ) ។ ក្នុងឆ្នាំ 2016 និងឆ្នាំ 2017 នេះ ធនាគារជាតិនៃកម្ពុជាបានអនុម័តវិធានការជាបន្តបន្ទាប់ ដែលត្រូវគេរំពឹងថានឹងជួយកាត់បន្ថយហានិភ័យដែលទាក់ទងទៅនឹងកំណើនឥណទានយ៉ាងឆាប់រហ័ស។

ការប្រែប្រួលអាកាសធាតុគួបផ្សំនឹងការរិចរិលធនធានធម្មជាតិ និងការអភិវឌ្ឍទីក្រុងដោយគ្មានផែនការ ក៏ត្រូវបានរំពឹងថានឹងប៉ះពាល់ដល់កំណើនក្នុងពេលអនាគតផងដែរ។ ការខូចខាតជាមធ្យមពីគ្រោះមហន្តរាយត្រូវបានប៉ាន់ស្មានថាមានចំនួនប្រមាណជា 235 លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ (Germanwatch, 2016)។ នៅពេលអនាគតការប្រែប្រួលអាកាសធាតុនឹងបង្កើនភាព

រូបលេខ 5. កម្ពុជាមានដំណាក់កាលបង្កើនទុនលឿនបំផុត ក្នុងចំណោមប្រទេសដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា (ខាងឆ្វេង) ទំហំឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង (ខាងស្តាំ)




*ប្រភព: អង្កេតលទ្ធភាពទទួលបានហិរញ្ញវត្ថុរបស់ IMF និងការគណនារបស់បុគ្គលិកធនាគារពិភពលោកផ្អែកលើ CSES 2004-14 ប្រភព: សូចនាករអភិវឌ្ឍន៍ពិភពលោក, ធនាគារជាតិនៃកម្ពុជា*

ងាយរងគ្រោះរបស់កម្ពុជាចំពោះគ្រោះមហន្តរាយធម្មជាតិ ដោយផ្អែកលើសេណារីយ៉ូនៃកំណើនសីតុណ្ហភាព 2 អង្សាសេ នៅឆ្នាំ 2050 ការប៉ាន់ស្មានបឋមបង្ហាញថា ការប្រែប្រួលអាកាសធាតុនឹងកាត់បន្ថយ ផសស សរុបរបស់កម្ពុជាយ៉ាងហោចណាស់ 1,5 ភាគរយ នៅឆ្នាំ 2030 និង 3,5 ភាគរយ នៅឆ្នាំ 2050 (RGC, 2015b)។ សម្បត្តិធម្មជាតិរបស់ប្រទេសកម្ពុជាក៏កំពុងត្រូវបានរិចរិលយ៉ាងឆាប់រហ័សដោយសកម្មភាពសេដ្ឋកិច្ចដែលគ្មាននិរន្តរភាព។ ការប៉ាន់ប្រមាណផ្លូវការបង្ហាញថាគម្របព្រៃឈើបានធ្លាក់ចុះពីជិត 60 ភាគរយ នៅក្នុងឆ្នាំ 2006 មកនៅតិចជាង 47 ភាគរយនៅឆ្នាំ 2014 និងប្រមាណជា 45 ភាគរយនៃតំបន់ដីសើមធម្មជាតិកាលពីដើមរបស់កម្ពុជាត្រូវបានបាត់បង់។ ការបាត់បង់បែបនេះមានផលប៉ះពាល់យ៉ាងធំធេងរាប់ទាំងលើផលិតភាពនៃវិស័យកសិកម្ម និងជលផល ការផលិតវារីអគ្គិសនី និងសម្បត្តិទេសចរណ៍។ ក្រៅពីនេះ នគរូបនីយកម្មអាចនាំមកនូវផលវិបាកអវិជ្ជមានចំពោះកំណើនសេដ្ឋកិច្ច។ ទោះបីជានគរូបនីយកម្មនៅកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយក្តី ដង់ស៊ីតេប្រជាជនជាមធ្យមនៅតំបន់ទីប្រជុំជនមានកម្រិតខ្ពស់ជាងនៅវៀតណាមនិងចិន រួចទៅហើយៗប្រជាជនជាច្រើនរស់នៅតំបន់ទីប្រជុំជនក្រីក្រ។

## ជាមួយនឹងបញ្ហាប្រឈមទាំងនេះ វិស័យអាទិភាពសម្រាប់ការអភិវឌ្ឍន៍ចំនួន 10 ត្រូវបានកំណត់:

ដោយផ្អែកលើការវិភាគស៊ីជម្រៅ និងការពិគ្រោះយោបល់ទូលំទូលាយ របាយការណ៍ការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) បានកំណត់ផ្នែកសំខាន់ៗនៃការអភិវឌ្ឍចំនួនដប់ ដើម្បីធានាឱ្យកំណើនមានរឹងមាំជាបរិយាប័ន្ននិងនិរន្តរភាពទៅអនាគត។ ការកំណត់អត្តសញ្ញាណនៃអន្តរាគមន៍អាទិភាពពាក់ព័ន្ធនឹងដំណើរការជាពីរជំហាន។ ទីមួយ ការងារវិភាគស៊ីជម្រៅ និងការពិនិត្យឡើងវិញនូវឯកសាររបាយការណ៍នានា រួមជាមួយដំណើរការពិគ្រោះយោបល់ទូលំទូលាយ[2] បានផ្តល់ព័ត៌មានសំរាប់ការជ្រើសរើសតំបន់អភិវឌ្ឍន៍ចំនួនដប់សម្រាប់ធ្វើសកម្មភាព។ ទីពីរ បន្ទាប់ពីការពិគ្រោះយោបល់ វិធីសាស្ត្រពីរថ្នាក់ត្រូវបានអនុវត្តដើម្បីវាយតម្លៃឧបសគ្គចំពោះកំណើន និងការបង្គរទ្រព្យសម្បត្តិ ព្រមទាំងកំណត់អាទិភាពបន្ទាន់បំផុតនៅក្នុងវិស័យទាំងដប់ដើម្បីអភិវឌ្ឍន៍ (តារាងលេខ 1)។ អន្តរាគមន៍ក្នុងតំបន់ដែលបានកំណត់សម្រាប់អភិវឌ្ឍន៍រួមចំណែកដល់ "លំអាន" ឬមធ្យោបាយផ្សេងគ្នាចំនួន 3 ដើម្បីសម្រេចបាននូវគោលដៅពីរយ៉ាងនៃការកាត់បន្ថយភាពក្រីក្រ និងវិបុលភាពរួមនៅក្នុងប្រទេសកម្ពុជា។ លំអានទាំងនេះក៏អាចទទួលបានអត្ថប្រយោជន៍ពីកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈពាក់ព័ន្ធ និងហិរញ្ញវត្ថុសាធារណៈដើម្បីពង្រឹងសមត្ថភាពនៃវិស័យសាធារណៈ។

### ការរកឃើញសំខាន់ៗ

"ប្រទេសកម្ពុជាបានជួបប្រទះនូវការប្រើប្រាស់ឥណទានលឿនបំផុតនៅក្នុងពិភពលោក"

2 ការចូលរួមច្រើនជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ (រដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងរដ្ឋសភា) រួមមានកិច្ចប្រជុំចំនួនប្រាំបួនដែលប្រព្រឹត្តទៅនៅក្នុងតំបន់ខុសៗគ្នាចំនួនបួននៃប្រទេសកម្ពុជា។ អ្នកចូលរួមបានផ្តល់មតិត្រឡប់អំពីឱកាសអភិវឌ្ឍន៍សំខាន់ៗដើម្បីសំរេចបាននូវការកាត់បន្ថយភាពក្រីក្រនិងកំណើនប្រកបដោយបរិយាប័ន្នតាមបែបមួយដែលមាននិរន្តរភាពនៅកម្ពុជា។

វិស័យសម្រាប់អភិវឌ្ឍន៍ត្រូវបានចាត់ថ្នាក់ដោយផ្អែកលើ (i) ផលប៉ះពាល់នៃបង្កើតនិងការលើកកំពស់ការចូលរួមរបស់គ្រួសារក្នុងឱកាសសេដ្ឋកិច្ច (ii) ភាគរយចំនួនប្រជាជនដែលរងផលប៉ះពាល់ និង (iii) ភាពបំពេញបន្ថែមជាមួយអន្តរាគមន៍ផ្សេងទៀត។ វិស័យសម្រាប់អភិវឌ្ឍន៍ដែលត្រូវបានកំណត់ថាជា "អាទិភាពខ្ពស់បំផុត" ទាំងនេះមានលទ្ធផលល្អខ្លាំងសំរាប់លើគោលដៅទាំងពីរក្នុងការជំរុញសមត្ថភាពរបស់ក្រុមហ៊ុន ដើម្បីបង្កើតការងារដែលមានផលិតភាពបន្ថែមទៀត រក្សាកំណើនសេដ្ឋកិច្ច និងបង្កើនប្រាក់ចំណូលគ្រួសារ។ វិស័យមាន "អាទិភាពខ្ពស់" ផ្តល់លទ្ធផលផ្ទាល់ភ្លាមៗសមល្មមមួយចំនួនចំពោះគោលដៅទាំងពីរ ប៉ុន្តែបង្កើតបានជាមូលដ្ឋានសម្រាប់កំណើនប្រកបដោយនិរន្តរភាព និងបង្កើនសមត្ថភាពរកប្រាក់ចំណូលគ្រួសារ។ វិស័យ "អាទិភាពកម្រិតមធ្យម" រួមមាន ទង្វើទាំងឡាយណាដែលនៅមិនទាន់អាចដោះស្រាយឧបសគ្គសំខាន់ៗបំផុតបាន ប៉ុន្តែមានផលវិបាកយូរអង្វែង ឬក៏ទង្វើទាំងឡាយណាដែលមានផលប៉ះពាល់ខ្ពស់ ប៉ុន្តែជាផលនៅនឹងកន្លែង។ ជម្រើសគោលនយោបាយមួយចំនួនដែលត្រូវបានជ្រើសរើសក្នុងវិស័យនីមួយៗនៃវិស័យទាំងដប់ មានបង្ហាញនៅក្នុងតារាងលេខ 1។ ការពិពណ៌នាសង្ខេបអំពីវិស័យនីមួយៗសម្រាប់ការអភិវឌ្ឍក៏មានបង្ហាញនៅខាងក្រោមនេះផងដែរ។

**តារាងលេខ 1: លំអានវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ និងការកំណត់វិស័យអាទិភាពសម្រាប់អភិវឌ្ឍន៍**

| លំអាន | វិស័យសម្រាប់អភិវឌ្ឍ | អាទិភាព | ជម្រើសគោលនយោបាយក្នុងវិស័យនេះ | |
|---|---|---|---|---|
| i. ការបង្កើនភាពប្រកួតប្រជែង និងពិពិធកម្មផ្នែកសេដ្ឋកិច្ចដើម្បីធានាបាននូវកំណើនខ្ពស់ និងបង្កើតការងារ | ១. ការកាត់បន្ថយចំណាយបង្កើតក្រុមហ៊ុន និងចំណាយប្រតិបត្តិការ (រួមមានបរិយាកាសអាជីវកម្ម ថ្លៃសេវាក្រៅផ្លូវការ កិច្ចសម្រួលពាណិជ្ជកម្ម ថ្លៃអគ្គិសនី) | ខ្ពស់បំផុត | ក្រុមការងារកែលម្អបរិយាកាសអាជីវកម្ម និងកាត់បន្ថយថ្លៃសេវាក្រៅផ្លូវការ | បង្កើតច្រកចេញចូលតែមួយសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម |
| | ២. ជំរុញវិនិយោគសាធារណៈនិងឯកជនចំពោះហេដ្ឋារចនាសម្ព័ន្ធនិងលទ្ធកម្មគ្រឿងម៉ាស៊ីន ព្រមទាំងអភិវឌ្ឍទីផ្សារទុន | ខ្ពស់ | អនុម័តអនុក្រឹត្យគ្រប់គ្រងវិនិយោគសាធារណៈ និងបង្កើតសៀវភៅណែនាំនិងនីតិវិធីនានា | បង្កើតទីផ្សារសញ្ញាបណ្ណផ្ទៃក្នុង (រួមទាំងរដ្ឋនិងឯកជន) |
| | ៣. ពង្រឹងនិយ័តកម្មនិងការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុដើម្បីកាត់បន្ថយហានិភ័យពីកំណើនយ៉ាងគំហុកឥណទាន ទន្ទឹមនឹងការកសាងបន្ថែមទៀតនូវបរិយាប័ន្នហិរញ្ញវត្ថុ | មធ្យម | ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ | លើកកម្ពស់ការត្រៀមលក្ខណៈសម្រាប់គ្រាមានវិបត្តិបង្កើតសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ |
| | ៤. ជំរុញការទំនើបកម្មកសិកម្មបន្ទាប់ពីការហក់ឡើងនៃថ្លៃទំនិញកសិកម្ម | ខ្ពស់ | សម្រួលចំណេះដឹងនិងអនុវត្តបច្ចេកវិទ្យានៅទូទាំងខ្សែសង្វាក់តម្លៃ (តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន- ក្រុមហ៊ុនជួយជំរុញអាជីវកម្ម សេវាផ្សព្វផ្សាយកសិកម្មពហុបែប | ពង្រឹងប្រព័ន្ធនិងសមត្ថភាពរបស់ភាគីពាក់ព័ន្ធងការគ្រប់គ្រងគុណភាពផលិតផលសុវត្ថិភាព និងហានិភ័យស្បៀងអាហារ |

តារាងលេខ 1: លំអានវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ និងការកំណត់វិស័យអាទិភាពសម្រាប់អភិវឌ្ឍន៍

| លំអាន | វិស័យសម្រាប់អភិវឌ្ឍ | អាទិភាព | ជម្រើសគោលនយោបាយក្នុងវិស័យនេះ | |
|---|---|---|---|---|
| ii. ការកសាងសម្បត្តិមនុស្សដើម្បីជួយសម្រួលដល់ចលភាពសេដ្ឋកិច្ចនិងវិបុលភាពរួម | ៥. ផ្តល់ជំនាញ តាមរយៈការបង្កើនលទ្ធផល និងលទ្ធផលរៀនសូត្រនៃការអប់រំកម្រិតមធ្យមនិងឧត្តមសិក្សា | ខ្ពស់បំផុត | អនុវត្តស្តង់ដារប្រសិទ្ធភាពនៅអនុវិទ្យាល័យ | ធ្វើឱ្យប្រសើរឡើងនូវយន្តការទទួលស្គាល់និងធានាគុណភាពនៅឧត្តមសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) |
| | ៦. ការវិនិយោគក្នុងឆ្នាំដំបូងៗ (អាហារូបត្ថម្ភ ការអប់រំនៅមត្តេយ្យសិក្សា) | ខ្ពស់ | អនុវត្តផែនទីចង្អុលផ្លូវលឿនដើម្បីលើកកម្ពស់អាហារូបត្ថម្ភ | ពង្រីកការទទួលបានឱកាសសម្រាប់ការរៀនសូត្រពីតូចនិងការជំរុញតាមរយៈមជ្ឈមណ្ឌលសហគមន៍ |
| | ៧. ការការពារគ្រួសារពីវិបត្តិ (ចំណាយប្រាក់ហោប៉ៅលើផ្នែកសុខភាព ការកាត់បន្ថយហានិភ័យ ការគាំពារសង្គម) | មធ្យម | ពង្រីកមូលនិធិសមធម៌សុខាភិបាលដល់ក្រុមងាយរងគ្រោះផ្សេងទៀត | ពង្រឹងប្រព័ន្ធកំណត់គោលដៅជនក្រីក្រ និងបង្កើតការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ |
| iii. ធានាឱ្យបាននូវលំនាំនៃកំណើននិរន្តរភាពតាមរយៈការវិនិយោគលើសម្បត្តិធម្មជាតិ ភាពធន់នឹងអាកាសធាតុនិងការអភិវឌ្ឍន៍ទីក្រុង | ៨. ថែរក្សានិងអភិវឌ្ឍសម្បត្តិធម្មជាតិ ខណៈពេលពង្រឹងភាពធន់នឹងអាកាសធាតុ | ខ្ពស់ | ទទួលយកវិធីសាស្ត្ររួមមួយ អនុវត្តអភិក្រមចម្រុះចំពោះការគ្រប់គ្រងធនធានធម្មជាតិនៅភ្នំក្រវាញនិងទន្លេសាប | កែលម្អការគ្រប់គ្រងនិងអភិរក្សដោយនិរន្តរភាពនូវតំបន់ការពារនិងព្រៃឈើ |
| | ៩. លើកកម្ពស់ទីក្រុងដែលមានការប្រកួតប្រជែង មាននិរន្តភាព និងទីក្រុងដែលមានការចូលរួមពេញលេញតាមរយៈការធ្វើផែនការសមាហរណកម្មទីក្រុង | មធ្យម | អនុវត្តកម្មវិធីកសាងផែនការសមាហរណកម្មទីក្រុង | អភិវឌ្ឍន៍បណ្តាញអនាម័យកណ្តាល (ថ្នាក់ជាតិ) និង ដោះស្រាយគ្រប់គ្រងកាក-សំណល់រឹងនិងរាវ |
| iv. ផ្នែកពាក់ព័ន្ធ | ១០. កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីលើកកម្ពស់ការផ្តល់សេវា | ខ្ពស់ | ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនិងដាក់ឱ្យប្រើប្រាស់ការត្រួតពិនិត្យសមិទ្ធកម្មការងារ | លើកកម្ពស់យន្តការឆ្លើយតបរបស់ប្រជាពលរដ្ឋដើម្បីកែលម្អការផ្តល់សេវាសាធារណៈ |

*ប្រភព: ការវិភាគរបស់បុគ្គលិកធនាគារពិភពលោកដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ*


SAIGON NEWPORT

## លំអានទី 1: ការបង្កើនភាពប្រកួតប្រជែង និងពិពិធកម្មផ្នែកសេដ្ឋកិច្ច ដើម្បីធានាបាននូវកំណើនខ្ពស់ និងបង្កើតការងារ

កំណើននៃការនាំចេញយ៉ាងឆាប់រហ័សគឺជាកត្តាជំរុញដ៏សំខាន់មួយនៃកំណើន និងការងារ ប៉ុន្តែមិនអាចមាននិរន្តរភាពទេ លុះត្រាតែសេដ្ឋកិច្ចកាន់តែមានលក្ខណៈប្រកួតប្រជែង និងមានភាពចម្រុះបែប។ ដូចបានរៀបរាប់ខាងលើ ប្រទេសកម្ពុជាត្រូវបានគេរំពឹងថានឹងមានការថយចុះនូវភាពអនុគ្រោះពាណិជ្ជកម្ម និងការកើនឡើងនៃថ្លៃពលកម្ម ជាមួយនិងការប្រកួតប្រជែងកាន់តែខ្លាំងក្លាក្នុងវិស័យកាត់ដេរពីប្រទេសជិតខាង ដូចជាពីប្រទេសវៀតណាម និងមីយ៉ាន់ម៉ា ជាដើម។ លើសពីនេះ ទៅទៀត ក្រោមរបបបណ្តែតអត្រាប្តូរប្រាក់ដែលស្ថិតក្រោមការគ្រប់គ្រង/ភ្ជាប់ជាមួយរូបិយបណ្ណដទៃ ការឡើងថ្លៃប្រាក់ដុល្លារអាមេរិក នាពេលថ្មីៗនេះធ្វើឱ្យទំនិញកម្ពុជាកាន់តែថ្លៃជាងមុននៅក្នុងទីផ្សារ អឺរ៉ុប និងធៀបជាមួយគូប្រជែងដទៃទៀត។ ដើម្បីទ្រទ្រង់កំណើនរឹងមាំ និងបង្កើតការងារ កម្ពុជាត្រូវបង្កើនភាពប្រកួតប្រជែងផ្នែកនាំចេញ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ការណ៍នេះអាចសម្រេចបានតាមរយៈវិធានការជាបន្តបន្ទាប់ ដែលជួយសម្រួលដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន ជំរុញការសន្សំប្រាក់ក្នុងស្រុក ក៏ដូចជាការវិនិយោគនៅក្នុងវិស័យពាណិជ្ជកម្មពង្រឹងនិយ័តកម្ម និងការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និងធ្វើទំនើបកម្មវិស័យកសិកម្ម។

ជាពិសេស ដើម្បីស្តារភាពប្រកួតប្រជែងឡើងវិញក្នុងរយៈពេលខ្លីទៅរយៈពេលមធ្យម តម្រូវការមួយក្នុងចំណោមតម្រូវការបន្ទាន់បំផុតគឺកាត់បន្ថយចំណាយបង្កើតក្រុមហ៊ុននិងចំណាយប្រតិបត្តិការ។ ការកាត់បន្ថយចំណាយបង្កើតក្រុមហ៊ុនអាចរួមមានវិធានការនានា ដូចជា ការបង្កើតច្រកចេញចូលតែមួយ ដើម្បីសម្រួលនីតិវិធី និងចំណាយសម្រាប់ការបើកអាជីវកម្ម និងកាត់បន្ថយឬលុបបំបាត់កាតព្វកិច្ចទុនអប្បបរមាដែលត្រូវតម្កល់នៅក្នុងធនាគារមុនពេលចុះបញ្ជីក្រុមហ៊ុន។ ប្រតិបត្តិការក្រុមហ៊ុននឹងត្រូវបានសម្រួលដោយការលុបចោលនីតិវិធីមិនចាំបាច់ លុបចោលថ្លៃក្រៅផ្លូវការ និងអំណោយនានា ដែលក្រុមការងារពិសេសមួយអាចត្រូវបានបង្កើតឡើង។ ការកាត់បន្ថយចំណាយនិងពេលវេលាពាក់ព័ន្ធក្នុងការធ្វើពាណិជ្ជកម្មឆ្លងដែនក៏មានសារៈសំខាន់ផងដែរ ដូចជាការបំពេញនីតិវិធីព្រំដែនដោយស្វ័យប្រវត្តិកម្ម ការលុបចោលតម្រូវការឯកសារមិនចាំបាច់ និងការបង្កើតក្រុមប្រឹក្សាភ័ស្តុភារកម្មជាតិមួយ ដើម្បីជួយធានាថាហេដ្ឋារចនាភ័ស្តុភាររឹង និងទន់របស់ប្រទេសកម្ពុជាទ្រទ្រង់ដល់ការពង្រីកពាណិជ្ជកម្ម។ ទីបំផុតសេចក្តីត្រូវការគឺចាំបាច់ត្រូវមានក្របខ័ណ្ឌស្ថាប័ន និងក្របខណ្ឌបទប្បញ្ញត្តិដែលមានលក្ខណៈរឹងមាំ ដើម្បីបង្កើនប្រសិទ្ធភាពថាមពល និងកាត់បន្ថយថ្លៃអគ្គិសនី។ វិធានការនានាអាចជា ការបង្កើតគោលនយោបាយបន្ថយថ្លៃក្នុងរយៈពេលមធ្យម ការបង្កើតផែនការពង្រីកប្រព័ន្ធរយៈពេលមធ្យម តាមរយៈការពិគ្រោះយោបល់ជាសាធារណៈ ការធានាថាគម្រោងធំៗ បានធ្វើលទ្ធកម្មក្នុងលក្ខណៈប្រកួតប្រជែង និងការបង្កើតគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់ជាមួយ ប្រទេសវៀតណាម ឡាវ និងថៃ។ ការវាយតម្លៃយ៉ាងពេញលេញនូវផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម និងកត្តាខាងក្រៅនៃជម្រើសថាមពលផ្សេងៗក៏មានសារៈសំខាន់ផងដែរ។

ដើម្បីជួយសម្រួលដល់ការបន្ថែមតម្លៃ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច អន្តរាគមន៍ទាំងនេះអាចត្រូវបានបំពេញបន្ថែមដោយកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញហេដ្ឋារចនាសម្ព័ន្ធ និងយន្តបភាវូបនីយកម្មទន្ទឹមនឹងការអភិវឌ្ឍទីផ្សារទុន។ ដើម្បីជៀសចាកពីការពឹងផ្អែកលើម្ចាស់ជំនួយចំពោះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងជួយជំរុញហេដ្ឋារចនាសម្ព័ន្ធតាមវិធីមួយដែលមានប្រសិទ្ធភាព និងនិរន្តរភាពនោះ ចាំបាច់ត្រូវបង្កើនវិនិយោគសាធារណៈ និងការគ្រប់គ្រងសម្បត្តិសាធារណៈ។ ការគ្រប់គ្រងវិនិយោគសាធារណៈចំពោះការវិនិយោគដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាល អាចត្រូវបានពង្រឹងតាមរយៈការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ ការបង្កើតសៀវភៅណែនាំអំពីការជ្រើសរើសនិងអនុវត្តគម្រោង និងការកសាងសមត្ថភាពនៅតាមក្រសួងសំខាន់ៗនិងក្រសួងពាក់ព័ន្ធ។ សម្រាប់គម្រោងដែលបានទទួលមូលនិធិពីបរទេស ការបង្កើនការសម្របសម្រួលជាមួយអ្នកផ្តល់ជំនួយ ការជៀសវាងការប្រើប្រាស់វិធីសាស្ត្រគ្មានលក្ខណៈជាប្រព័ន្ធក្នុងការជ្រើសរើសគម្រោងនឹងការធានាឱ្យមានប្រតិបត្តិការ និងថវិកាថែទាំបានគ្រប់គ្រាន់ នឹងអាចជួយធានាប្រសិទ្ធភាព និងនិរន្តរភាពរបស់គម្រោង។ ប្រទេសកម្ពុជាក៏អាចរៀបចំការលើកទឹកចិត្តពន្ធដែលមានស្រាប់របស់ខ្លួននៅក្នុងច្បាប់វិនិយោគថ្មី (ដូចដែលបានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រដ្ឋាភិបាល) បង្វែរទិសពីការផ្តល់ឱ្យរយៈពេលនៃការលើកលែងពន្ធលើប្រាក់ចំណេញ ទៅកាន់ប្រព័ន្ធលើកទឹកចិត្តមួយ ដែលជំរុញការវិនិយោគឯកជនលើផ្នែកគ្រឿងម៉ាស៊ីន ស្រាវជ្រាវ និងអភិវឌ្ឍន៍ និងការបណ្តុះបណ្តាល។ ការណ៍នេះនឹងជួយបង្កើនផលិតភាពនិងជំរុញការធ្វើពិពិធកម្មដោយលើកទឹកចិត្តដល់ការវិនិយោគនៅក្នុងវិស័យមានតម្លៃបន្ថែមខ្ពស់។ លើសពីនេះទៀត ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ និងការបង្កើតទីផ្សារសញ្ញាបណ្ណផ្ទៃក្នុង នឹងជួយជំរុញការសន្សំប្រាក់ក្នុងស្រុក និងផ្តល់នូវកម្រិតប្រែប្រួលនៃអត្រាប្តូរប្រាក់កាន់តែខ្ពស់ក្នុងរយៈពេលមធ្យម ដែលនឹងជួយឱ្យសេដ្ឋកិច្ចទទួលបានមកវិញនូវភាពប្រកួតប្រជែងក្នុងបរិបទនៃការឡើងថ្លៃប្រាក់ដុល្លារអាមេរិកក្រោមដុល្លាររូបនីយកម្ម។

ជាមួយគ្នានេះ ការកាត់បន្ថយហានិភ័យពីកំណើនឥណទានខ្ពស់ខណៈបង្កើនបរិយាប័ន្ន ហិរញ្ញវត្ថុក៏មានសារៈសំខាន់ផងដែរ។ ខណៈដែលកំណើនឥណទានឆាប់រហ័សជាកត្តាចំបងមួយដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ចនោះសេចក្តីចាំបាច់គឺ ត្រូវដោះស្រាយបញ្ហាដែលអាចកើតមានជាពិសេស ហានិភ័យដែលកើតចេញពីវិស័យសំណង់ដែលមានសក្តានុពលមិនរឹងមាំ និងមានការជាប់បំណុលច្រើនហួស ដែលអាចប៉ះពាល់ដល់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ប៉ះពាល់ដល់គ្រួសារក្រីក្រ និងប៉ះពាល់ដល់បរិស្ថាន។ ចាំបាច់ត្រូវពង្រឹងការត្រួតពិនិត្យធនាគារ និងមីក្រូហិរញ្ញវត្ថុដូចជាតាមរយៈវិធីសាស្ត្រត្រួតពិនិត្យមើលហានិភ័យ ដែលអនុលោមតាមស្តង់ដារអន្តរជាតិបេសែល (Basel) ចុងក្រោយបំផុត។ វិធានការជាបន្តបន្ទាប់នៃភាពប្រុងប្រយ័ត្នផ្នែកម៉ាក្រូ គុណភាពទិន្នន័យ និងវិធានការត្រួតពិនិត្យ ក៏នឹងជួយពង្រឹងស្ថិរភាពវិស័យហិរញ្ញវត្ថុរួមទាំងការដាក់កម្រិតលើកម្ចីពីច្រើនប្រភព និងការណែនាំពីការកម្រិតទំហំប្រាក់កម្ចីធៀបនឹងនិងប្រាក់ចំណូល ចំពោះការឱ្យគ្រួសារខ្ចី។ អាជ្ញាធរក៏អាចពិចារណាលើការបង្កើតបទប្បញ្ញត្តិបន្ថែមសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ និងអនុវត្តគោលការណ៍ណែនាំក្នុងការខ្ចីប្រាក់ ដើម្បីទប់ស្កាត់ការចងការបែបជញ្ជក់ឈាម

ចំពោះគ្រួសារដែលមានសមត្ថភាពតិចតួចក្នុងការសងបំណុល។ ទន្ទឹមនឹងនេះ ក៏មានសេចក្តីត្រូវការក្នុងការគាំទ្រដើម្បី ការត្រៀមលក្ខណៈចំពោះវិបត្តិ ការបង្កើតសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ និងការពង្រឹងបរិយាប័ន្នហិរញ្ញវត្ថុ ដូចជា តាមរយៈការសម្របសម្រួលឱ្យទទួលបានសេវាធនាគារ និងធនាគារចល័តតាមរយៈហិរញ្ញវត្ថុឌីជីថល ជាដើម។

ទន្ទឹមនឹងនេះផ្អែកលើសារៈសំខាន់ជាបន្តនៃវិស័យកសិកម្មចំពោះកំណើន និងការកាត់បន្ថយភាពក្រីក្រ កម្ពុជាត្រូវជំរុញការធ្វើទំនើបកម្មកសិកម្ម។ ឥឡូវនេះ ដោយការកើនថ្លៃគំហុកកសិផលបានកន្លងទៅហើយប្រភព និងកត្តាផ្សេងទៀតដែលជំរុញកំណើនកសិកម្ម ចាំបាច់ត្រូវថែបំប៉ន។ ជាពិសេស ធារាសាស្ត្រអាចដើរតួនាទីកាន់តែធំក្នុងការជំរុញផលិតភាពកសិកម្ម និងពិពិធកម្ម ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់។ វិធានការមួយចំនួនអាចជួយក្នុងករណីនេះ ដោយអនុវត្តនីតិវិធីច្បាស់លាស់ និងការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ការបង្កើនជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រុមកសិករប្រើប្រាស់ទឹក និងសម្រួលដល់ការអនុវត្តបច្ចេកវិទ្យាធារាសាស្ត្រខ្នាតតូចដទៃទៀត។ ដើម្បីជំរុញកំណើនផលិតកម្មកាន់តែទូលំទូលាយក្នុងវិស័យកសិកម្ម ចាំបាច់ត្រូវមានអន្តរាគមន៍ជួយសម្រួលចំណេះដឹងនិងការអនុវត្តបច្ចេកវិទ្យា។ ទម្រង់បែបបទមិនមែនប្រពៃណី (និងមិនមែនរដ្ឋ) នៃការផ្តល់ប្រឹក្សាផ្នែកកសិកម្ម និងសេវាកម្មបច្ចេកទេសផ្សេងទៀត អាចត្រូវបានលើកទឹកចិត្ត រួមទាំង បច្ចេកវិទ្យាសម្រាប់អនុវត្តផងដែរ។ បណ្តាញសម្របសម្រួលដល់កិច្ចសហការរវាងវិស័យសាធារណៈ វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវអនុវត្តកសិកម្ម និងការបង្កើតថ្មី ក៏នឹងមានសារៈសំខាន់ផងដែរសម្រាប់បង្កើនផលិតភាព។ អាទិភាពមួយទៀតគឺពង្រឹងបរិមាណទំនិញសាធារណៈសំខាន់ៗ ខណៈបែងចែកឱ្យដាច់រវាងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មកម្ពុជា ដោយផ្អែកលើគុណភាព ឧទាហរណ៍ តាមរយៈការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងគុណភាព និងសុវត្ថិភាពម្ហូបអាហារ។ ស្របពេលជាមួយគ្នានេះ ជារួម វិស័យកសិកម្ម និងប្រព័ន្ធស្បៀងអាហារ គួរដើរតួនាទីឱ្យកាន់តែខ្លាំងឡើងក្នុងការកែលម្អលទ្ធផលអាហារូបត្ថម្ភក្នុងស្រុក ដោយរដ្ឋាភិបាលជួយធានាថាមានអាហារដែលមានសារធាតុចិញ្ចឹមសម្បូណ៌បែប និងមានតំលៃសមរម្យ ហើយអតិថិជនយល់ដឹងអំពីសារៈសំខាន់នៃរបបអាហារទាំងនេះរបស់ខ្លួន។



## លំអានទី 2: ការកសាងសម្បត្តិមនុស្សដើម្បីជួយសម្រួលដល់ចលភាពសេដ្ឋកិច្ច និងវិបុលភាពរួម

ធនធានមនុស្សរឹងមាំមានសារៈសំខាន់ណាស់ មិនត្រឹមតែបង្កលក្ខណៈឱ្យប្រជាជនទទួលយកឱកាសការងារកាន់តែប្រសើរក្នុងវិស័យមិនមែនកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយសម្រួលដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារផងដែរ។ ប្រទេសកម្ពុជាមានឱកាសលើកកម្ពស់គុណភាពនៃការសិក្សា និងបង្កើនការទទួលបានការអប់រំ ដើម្បីជួយបង្កើនឱកាសដល់ពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះផ្នែកសេដ្ឋកិច្ចឱ្យមានសន្តិសុខផ្នែកសេដ្ឋកិច្ច។ ការងារបែបនេះប្រហែលជាមិនស្របតាមយុទ្ធសាស្ត្រពិពិធកម្ម និងភាពប្រកួតប្រជែងនោះទេ ប៉ុន្តែវានឹងផ្តល់ឱកាសសេដ្ឋកិច្ចដល់មនុស្សមួយចំណែកធំ ដែលស្ថិតនៅក្រៅខ្សែសង្វាក់តម្លៃសកល។ អាទិភាពថ្មីៗសម្រាប់សំធចគោលដៅនេះ គឺការផ្តោតការយកចិត្តទុកដាក់ជាថ្មីលើការវិនិយោគក្នុងពេលដែលកុមារនៅតូច និងបង្កើនអន្តរកាលទៅកាន់ និងបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) ប្រកបដោយគុណភាពខ្ពស់។ ការណ៍នេះក៏ទាមទារឱ្យមានការកែលម្អក្នុងការផ្តល់សេវាសាធារណៈ ហើយអាចបំពេញបន្ថែមដោយការពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គម មិនត្រឹមតែគ្រាន់តែកាត់បន្ថយភាពងាយរងគ្រោះនោះទេ តែថែមទាំងធ្វើឱ្យមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំដែលមានគុណភាពខ្ពស់ និងកែលម្អលទ្ធផលអាហារូបត្ថម្ភសម្រាប់អ្នកក្រផងដែរ។

អាទិភាពចម្បងមួយគឺផ្តល់ការគាំទ្រដល់អ្នកដែលមានជំនាញ តាមរយៈការបង្កើនការទទួលបាន និងលទ្ធផលរៀនសូត្រនៃការអប់រំកម្រិតមធ្យមនិងឧត្តមសិក្សា។ ការដោះស្រាយឧបសគ្គ ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការដើម្បីទទួលបានការអប់រំគឺជាគន្លឹះ។ អាទិភាពមួយនៃផ្នែកតំរូវការគឺ ផ្លាស់ប្តូរកត្តាលើកទឹកចិត្តដើម្បីឱ្យអ្នកក្រីក្រវិនិយោគលើការអប់រំបន្ថែមទៀត និងធ្វើឱ្យការអប់រំកាន់តែមានតម្លៃសមរម្យសម្រាប់ពួកគេ ឧទាហរណ៍ តាមរយៈការកំណត់អាទិភាពផ្តល់ជំនួយដល់សាលារៀនដែលបង្កលក្ខណៈអំណោយផលដល់សិស្សក្រីក្រ និងការកំណត់មុខសញ្ញាកម្មវិធីអាហារូបករណ៍ថ្នាក់ជាតិឱ្យកាន់តែមានសមធម៌។ ផ្នែកផ្គត់ផ្គង់ ចាំបាច់ត្រូវមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព និងការពង្រីកស្តង់ដារប្រសិទ្ធភាពសាលាមធ្យមសិក្សាបឋមភូមិ ដើម្បីពង្រឹងប្រព័ន្ធផ្តល់សេវាអប់រំ និងតម្រូវឱ្យសាលារៀនទទួលខុសត្រូវ ចំពោះការរៀនសូត្ររបស់សិស្ស។ គុណភាព និងភាពពាក់ព័ន្ធនៃការអប់រំឧត្តមសិក្សា ក៏អាចត្រូវបានលើកកម្ពស់តាមរយៈស្វ័យភាពកាន់តែធំសម្រាប់គ្រឹះស្ថានឧត្តមសិក្សា សាធារណៈ ការពង្រឹងយន្តការទទួលស្គាល់គុណភាពអប់រំ និងយន្តការធានាគុណភាព និងការប្រើប្រាស់ធនធានសាធារណៈកាន់តែសកម្មដើម្បីជំរុញមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ។ ដើម្បីលើកកម្ពស់ការអប់រំជាទូទៅ ការតម្រូវការផ្គត់ផ្គង់ការបណ្តុះបណ្តាលជំនាញជាមួយនឹងតម្រូវការរបស់និយោជក រួមទាំងការពង្រឹងតួនាទីរបស់អន្តរការី ក៏ចាំបាច់ផងដែរ។ ជម្រើសមួយគឺសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានាផ្តល់ឧបត្ថម្ភធន លើការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះ

បណ្តាលវិស័យជាក់លាក់ដើម្បីធានាថា ការបណ្តុះបណ្តាលស្របតាមតម្រូវការរបស់និយោជក និងស្របតាមនិន្នាការវិស័យ និងកំណើន។

អាទិភាពមួយទៀតសម្រាប់ការកសាងសម្បត្តិមនុស្ស គឺត្រូវវិនិយោគតាំងពីពេលកុមារនៅតូចបង្ការឧបសគ្គចំពោះការអភិវឌ្ឍរបស់កុមារ។ ការណ៍នេះតម្រូវប្រាកដថាកុមារទទួលបានអាហារូបត្ថម្ភល្អ ចាប់ផ្តើមទៅសាលារៀនពេលនៅតូច (ពេលវេលាសំខាន់សម្រាប់ការអភិវឌ្ឍខួរក្បាល) និងត្រូវមានបរិយាកាសរៀនសូត្រគ្រប់គ្រាន់។ ចំពោះផ្នែកអាហាររូបត្ថម្ភ យន្តការផ្អែកលើលទ្ធផល ដូចជា ជំនួយផ្តល់សេវា និងមូលនិធិសមធម៌សុខាភិបាល (HEFs) អាចត្រូវបានប្រើដើម្បីលើកកម្ពស់វត្តមាន និងគុណភាពនៃសេវា ដែលបានរៀបរាប់នៅលើផែនទីចង្អុលផ្លូវតាមបែបរហ័សដើម្បីលើកកម្ពស់អាហារូបត្ថម្ភ[3]។ ការផ្តល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាល ក៏អាចត្រូវបង្កើនសម្រាប់ការងារ ទំនាក់ទំនងសង្គម និងការផ្លាស់ប្តូរឥរិយាបថ សំដៅធ្វើឱ្យមានសុខដុមនីយកម្មរវាងសារនានាដែលទាក់ទងនឹងអាហារូបត្ថម្ភនៅតាមវិស័យផ្សេងៗ។ ការលើកកម្ពស់ផ្នែកផ្គត់ផ្គង់បែបនេះ អាចបំពេញបន្ថែមដោយកត្តាលើកទឹកចិត្តផ្នែកតម្រូវការ (ឧទាហរណ៍ ការផ្ទេរសាច់ប្រាក់ដែលបានគ្រោង ប្រាក់ឧបត្ថម្ភសម្រាប់ដឹកជញ្ជូន និងការលើកទឹកចិត្តកម្រិតសហគមន៍ ដូចជាមូលនិធិក្រុមប្រឹក្សាឃុំ / មូលនិធិសង្គមថ្នាក់ឃុំ) ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថ និងការប្រើប្រាស់សេវាសំខាន់ៗសម្រាប់កុមារតូច។ ដើម្បីពង្រីកការទទួលបានឱកាសរៀនសូត្រ និងការជំរុញពេលនៅតូច ទម្រង់បែបបទមិនមែនស្ថាប័ន ដូចជាកម្មវិធីអប់រំតាមផ្ទះ / កម្មវិធីអប់រំមាតាបិតា និងសាលាមត្តេយ្យសហគមន៍ អាចត្រូវបានប្រើប្រាស់ និងពង្រីកនៅតាមជនបទ។ កត្តាសំខាន់មួយទៀតសម្រាប់អាហារូបត្ថម្ភរបស់កុមារ គឺការទទួលបានទឹក និងអនាម័យ ដែលអាចត្រូវបានលើកកម្ពស់ដោយការបង្កើតកម្មវិធីដែលមានការឧបត្ថម្ភថវិកាច្រើន សម្រាប់អនុវត្តផែនការសកម្មភាពជាតិសម្រាប់ទឹកស្អាត និងអនាម័យជនបទ ការពង្រីកសេវាកម្ម ទឹកម៉ាស៊ីននៅតាមតំបន់ជនបទ និងការកសាងសមត្ថភាពចំពោះប្រតិបត្តិករទឹក ដើម្បីលើកកំពស់សមិទ្ធកម្ម និងប្រសិទ្ធភាពនៃសេវាកម្ម។

---

3 ផែនទីចង្អុលផ្លូវល្បឿនលឿនសម្រាប់ការលើកកម្ពស់អាហារូបត្ថម្ភ (2014-2020) បង្ហាញកញ្ចប់អន្តរាគមន៍អាហារូបត្ថម្ភចំនួនប្រាំដែលត្រូវផ្តល់តាមទំហំ: (i) ការផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភក្នុងកំឡុងពេលថែទាំមុនសម្រាល; (ii) ការបន្ថែមមីក្រូសារជាតិនិងការបញ្ចុះព្រូនម្តាយនិងទារកទើបនឹងកើត; (iii) ការព្យាបាលកុមារក្រិន (iv) ការបំប៉នមីក្រូសារជាតិសម្រាប់យុទ្ធសាស្ត្របង្ការនិងព្យាបាល និង (v) ការផ្លាស់ប្តូរឥរិយាបថផ្តោតលើឱកាស 1.000 ថ្ងៃ។ សកម្មភាពបន្ថែមចំនួនបីត្រូវបានស្នើឡើងដើម្បីជួយបង្កលក្ខណៈពង្រីកកញ្ចប់ទាំងនេះ៖ (vi) ដកឧបសគ្គផ្នែកហិរញ្ញវត្ថុនិងធនធានមនុស្សដើម្បីពង្រីកអន្តរាគមន៍ដែលមានប្រសិទ្ធភាព (vii) ជំរុញការគាំទ្រតាមរយៈក្រសួងនិងគំនិតផ្តួចផ្តើមដទៃ និង (viii) កែលម្អទិន្នន័យអាហារូបត្ថម្ភនៅក្នុងប្រព័ន្ធព័ត៌មានដែលមានស្រាប់។

បន្ថែមលើការកសាងសម្បត្តិទ្រព្យរបស់ពលរដ្ឋក្រីក្រ និងក្បែរក្រីក្រ ការជួយពួកគេថែរក្សាចំណូលក៏ជាសេចក្តីត្រូវការចាំបាច់ដែរ។ វិធានការសំដៅកាត់បន្ថយវិបត្តិ និងកសាងភាពធន់ នឹងអាចជួយការពារប្រាក់ចំណូលគ្រួសារ និងបង្ការគ្រួសារមិនឱ្យធ្លាក់ចូលក្នុងភាពក្រីក្រ។ ដើម្បីជំរុញការគាំពារផ្នែកហិរញ្ញវត្ថុចំពោះការចំណាយដ៏ច្រើនលើសលប់លើបញ្ហាសុខភាព មូលនិធិសមធម៌សុខាភិបាលអាចត្រូវបានពង្រីកដោយមានកញ្ចប់អត្ថប្រយោជន៍កាន់តែច្រើន សម្រាប់ពលរដ្ឋក្រីក្រ និងការគាំពារជាមូលដ្ឋានចំពោះក្រុមងាយរងគ្រោះដទៃទៀត។ ជាមូលដ្ឋានមួយសម្រាប់ពង្រីកវិសាលភាពនៃសំណាញ់សុវត្ថិភាព គប្បីពិនិត្យមើលឡើងវិញ និងកែសម្រួលនូវប្រព័ន្ធកំណត់អត្តសញ្ញាណពលរដ្ឋក្រីក្រ ក្នុងគោលបំណងរៀបចំបញ្ជី និងចំណាត់ថ្នាក់ពលរដ្ឋក្រីក្រ និងមិនក្រីក្រ ដែលមានទំនាក់ទំនង ជាមួយប្រព័ន្ធចុះបញ្ជីពលរដ្ឋ និងអាចប្រើសម្រាប់គ្រប់កម្មវិធីសំណាញ់សុវត្ថិភាពសាធារណៈ។ កម្មវិធីគាំពារសង្គមមួយទៀតសម្រាប់ពិចារណាគឺកម្មវិធីផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ ដែលអាចផ្តល់សុវត្ថិភាពច្រើនសម្រាប់ពលរដ្ឋក្រីក្រ ជួយបន្ថយផលប៉ះពាល់នៃវិបត្តិ ព្រមទាំងជំរុញឥរិយាបថដែលគួរឱ្យចង់បាន ដូចជាការចូលរៀន ឬទម្លាប់ក្នុងការផ្តល់អាហារប្រឆាំងនឹងជំងឺក្រិន ជាដើម។ ការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌក៏អាចជាមធ្យោបាយមួយក្នុងការប្រគល់សម្រាប់គម្រោងមួយចំនួន (ដូចជាប្រាក់សោធនសាធារណៈសម្រាប់មនុស្សចាស់ជរាក្រីក្រ ការគាំទ្រដល់ជនពិការ ការគាំទ្រដល់គ្រួសារក្រីក្រដែលមានស្ត្រីមានផ្ទៃពោះ និង / ឬមានកុមារតូចៗ)។ ក្នុងការរៀបចំសម្រាប់វ័យចំណាស់ ចាំបាច់ក៏ត្រូវមានកំណែទម្រង់សោធននិវត្តន៍ផងដែរ ដោយចាប់ផ្តើមជាមួយការធ្វើសុខដុមនីយកម្មនៃគម្រោងដែលកំពុងដំណើរការផ្សេងគ្នា ក្នុងគោលបំណងសម្រេចបាននូវចលភាពពេញលេញ។ លើសពីនេះ ការប្រឈមមុខនឹងគ្រោះមហន្តរាយធម្មជាតិអាចត្រូវបានកាត់បន្ថយតាមរយៈការកសាងផែនការ និងការរៀបចំប្លង់ដែលគិតគូរអំពីហានិភ័យហើយការខិតខំបន្ថែមទៀតអាចសំដៅបង្កើនសមត្ថភាពវាយតម្លៃហានិភ័យ និងលើកកំពស់សមត្ថភាពត្រៀមលក្ខណៈទប់ទល់នឹងគ្រោះមហន្តរាយ និងការឆ្លើយតបឆាប់រហ័សផ្នែកសារពើពន្ធ។



## លំអានទី 3: ធានាឱ្យបាននូវលំនាំនៃកំណើននិរន្តរភាពតាមរយៈការវិនិយោគលើសម្បត្តិធម្មជាតិ ភាពធន់នឹងអាកាសធាតុ និងការអភិវឌ្ឍន៍ទីក្រុង

ប្រទេសកម្ពុជាប្រឈមនឹងការសម្រេចចិត្តសំខាន់ៗជាច្រើនស្តីពីការថ្លឹងថ្លែងរវាងការគាំទ្រតម្រូវការស្បៀងអាហារ ថាមពល និងតម្រូវការទឹក ខណៈត្រូវអភិរក្សប្រព័ន្ធធម្មជាតិរបស់ខ្លួនផងដែរ។ ដូចបានពិភាក្សាខាងដើម នៅពេលដែលការអភិវឌ្ឍន៍ទីក្រុងបានរួមចំណែកយ៉ាងច្រើនដល់កំណើន និងការកាត់បន្ថយភាពក្រីក្រ សកម្មភាពសេដ្ឋកិច្ច និងវិធីគ្រប់គ្រងដែលគ្មាននិរន្តរភាពបានធ្វើឱ្យធនធានធម្មជាតិរបស់ប្រទេសកម្ពុជាធ្លាក់ចុះជាខ្លាំង ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ បន្ថែមលើបញ្ហាទាំងនេះ ត្រូវបាន រំពឹងថា នឹងមានការផ្លាស់ប្តូររបបទឹកនៅកម្ពុជាពីទន្លេមេគង្គ ដោយមានផលប៉ះពាល់ពីការអភិវឌ្ឍវារីអគ្គិសនីនៅខ្សែទឹកខាងលើ និងការបង្កើនការប្រើប្រាស់ទឹកសម្រាប់តម្រូវការកសិកម្ម និងតម្រូវការប្រើប្រាស់ទឹកនៅតាមគ្រួសារ។ ដោយសារមានទំនាក់ទំនងគ្នារវាងប្រព័ន្ធអេកូឡូស៊ីផ្អែកលើធនធានធម្មជាតិ និងបរិស្ថានទីក្រុងដែលបង្កើតដោយមនុស្ស ការដោះស្រាយបញ្ហាប្រឈមទាំងនេះតម្រូវឱ្យមានវិធីសាស្ត្រទីតាំងចម្រុះ។ ចំពោះធនធានធម្មជាតិ ប្រការនេះមានន័យថាជាការគិតគូរពីបញ្ហាប្រឈមធម្មជាតិ និងការដោះដូរពាក់ព័ន្ធនឹងការធ្វើទំនើបកម្មកសិកម្ម ការលើកកម្ពស់វិស័យជលផល ការពង្រីកវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍន៍វារីអគ្គិសនីនៅក្នុងភូមិសាស្ត្រជាក់លាក់ ក្នុងការសម្របសម្រួលជាមួយការគ្រប់គ្រង និងការស្តារឡើងវិញនូវព្រៃរិចរឹល និងប្រព័ន្ធវារីអេកូឡូស៊ី និងការពង្រឹងភាពធន់ចំពោះការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្មជាតិ។ ចំពោះការធ្វើផែនការទីក្រុង ប្រការនេះមានន័យថាជាការបង្កើតយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អនុវត្តកំណែទម្រង់នៅគ្រប់វិស័យទីក្រុងរួមមាន វិស័យទឹក អនាម័យ ការដឹកជញ្ជូន និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងទីក្រុងមួយជាក់លាក់។ ជាមួយវិធានការបែបនេះ ប្រទេសកម្ពុជានឹងពង្រឹងសមត្ថភាពរបស់ខ្លួនជាខ្លាំងក្នុងការសម្រេចបាននូវគោលដៅកំណើនរយៈពេលវែង និងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ខ្លួន រួមជាមួយការបន្សុំនឹងអាកាសធាតុ និងការប្តេជ្ញាចិត្តកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងការរួមចំណែកដែលបានកំណត់នៅថ្នាក់ជាតិ (NDC)។

កិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្ត និងពង្រីកកំណែទម្រង់ថ្នាក់ជាតិដែលមានស្រាប់នៅកម្ពុជា និងកម្មវិធីនានាស្តីពីធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារសម្បត្តិធម្មជាតិរបស់ប្រទេស។ ឧទាហរណ៍ ការបង្កើតកម្មវិធីចំណាយសាធារណៈដែលបានកំណត់នឹងអាចជួយដោះស្រាយបញ្ហាកង្វះខាតហិរញ្ញប្បទានសម្រាប់យុទ្ធសាស្ត្រជាតិ ផែនការសកម្មភាព និងការអនុវត្តន៍របស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងសម្បត្តិធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងកំណើនបៃតង ក៏ដូចជាការបង្កើនការគាំទ្រដល់អាជ្ញាធរមូលដ្ឋានសម្រាប់ការអនុវត្តន៍ផងដែរ។ ដើម្បីកាត់បន្ថយចំណាយខ្ពស់នៃសកម្មភាពសេដ្ឋកិច្ចដែលគ្មាននិរន្តរភាព ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានដែលមានលក្ខណៈជាយុទ្ធសាស្ត្រអាចត្រូវបានរៀបចំឡើងសម្រាប់គម្រោងសាធារណៈ និងឯកជនទាំងអស់ដែលមានផលប៉ះពាល់លើបរិស្ថាន និងជីវភាពរស់នៅ។ ចំពោះវិស័យព្រៃឈើ ចាំបាច់ត្រូវមានការខិតខំ

ប្រឹងប្រែងបន្ថែមទៀតក្នុងការប្រយុទ្ធប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ និងឆ្ពោះទៅរកនិរន្តរភាព ឧទាហរណ៍ តាមរយៈការបង្កើតផែនការយុទ្ធសាស្ត្រ និងក្របខ័ណ្ឌគោលនយោបាយសម្រាប់គ្រប់គ្រងអភិរក្សច្រករបៀង ការពង្រីកឱកាសចិញ្ចឹមជីវិតបែបផ្សេងពីផលិតផលមិនមែនព្រៃឈើ និងអេកូទេសចរណ៍ ការធ្វើឱ្យប្រសើរឡើងនូវកែច្នៃកតំបន់ប្រើប្រាស់ដីធ្លី និងសិទ្ធិកាន់កាប់ដីធ្លី និងការអភិវឌ្ឍន៍ចម្ការឈើដាំប្រកបដោយនិរន្តភាពសម្រាប់យកអុស និងដើមឈើ។ ការគ្រប់គ្រងធនធានទឹក និងធនធានជលផលដែលមានផលិតភាពខ្ពស់របស់ប្រទេសកម្ពុជាក៏តម្រូវឱ្យមានការអនុវត្តផែនការ គោលនយោបាយដែលមានស្រាប់ និងការអនុវត្តជាក់ស្តែងសម្រាប់ប្រព័ន្ធអេកូឡូស៊ីទន្លេមេគង្គ និងទន្លេសាបផងដែរ។ ជាជំហ៊ានដំបូង កម្ពុជាគួរបន្តលើកកម្ពស់ការអនុវត្តការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ជាពិសេសតាមរយៈការគាំទ្របន្ថែមទៀតចំពោះប្រព័ន្ធព័ត៌មានស្តីពីទឹក និងការកសាងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន។ សំខាន់ដោយសារតែស្ថានភាពទឹកដីនៅកម្ពុជាមានទំនាក់ទំនងគ្នាទៅវិញទៅមក វិធីសាស្ត្រសមាហរណកម្មលំហចំពោះការគ្រប់គ្រងធនធានធម្មជាតិគឺជាការចាំបាច់ តាមរយៈការគ្រប់គ្រងរួមគ្នាកាន់តែរឹងមាំ មិនសូវដាច់ដោយដុំ និងមានគោលដៅរួមក្នុងវិស័យផ្សេងៗរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន។

កំណើនប្រកបដោយចីរភាពក៏នឹងពឹងផ្អែកលើការអភិវឌ្ឍទីក្រុង ដែលមានភាពប្រកួតប្រជែងមាននិរន្តរភាព និងប្រកបដោយបរិយាប័ន្ន តាមរយៈការធ្វើផែនការសមាហរណកម្មទីក្រុង។ កម្មវិធីផែនការសមាហរណកម្មទីក្រុងគួរប្រមែប្រមូលផែនការប្រើប្រាស់ដី និងផែនការទប់ទល់នឹងគ្រោះមហន្តរាយដោយការវិនិយោគលើបណ្តាញដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ។ មកទល់ពេលនេះមានតែរាជធានីភ្នំពេញនិងបាត់ដំបងប៉ុណ្ណោះដែលបានបង្កើតផែនការមេរាជធានីនិងទីក្រុងលម្អិតដែលមានវឌ្ឍនភាពតិចតួចក្នុងការអនុវត្ត។ ស្របគ្នានេះដែរ ផែនការមេសម្រាប់ដឹកជញ្ជូនក្នុងទីក្រុង ការគ្រប់គ្រងកាកសំណល់រឹងប្រព័ន្ធបង្ហូរទឹកនិងលូទឹក និងផែនការផ្គត់ផ្គង់ទឹក ត្រូវបានបង្កើតឡើងសម្រាប់រាជធានីភ្នំពេញ។ ការពង្រឹងការសម្របសម្រួលនិងការអនុវត្តផែនការទាំងនេះមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងទីក្រុង។ យន្តការស្ថាប័ន រឹងមាំ និងយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិត ដូចជាភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ក៏ចាំបាច់ផងដែរ ដោយសារតែក្រុងភាគច្រើនពុំមានធនធានគ្រប់គ្រាន់ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរបស់ពួកគេ ឬសម្រាប់វិនិយោគទុនគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ។ នៅក្នុងក្របខណ្ឌនៃផែនការសមាហរណកម្មទាំងនេះ វិស័យអាទិភាព រួមមានអនាម័យទីក្រុង និងការដឹកជញ្ជូននៅតាមទីប្រជុំជន ក៏ដូចជាការលើកកំពស់ការតាំងទីលំនៅក្រីក្រនៅទីប្រជុំជននិងការអនុវត្តដំណើរការចុះបញ្ជីដីធ្លី និងចេញប័ណ្ណកម្មសិទ្ធិដោយតម្លាភាពនិងដោយមានការសម្របសម្រួល។

## ផ្នែកពាក់ព័ន្ធ: កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីកែលម្អការផ្តល់សេវា

រាល់អាទិភាពនៃកំណែទម្រង់ ដែលបានកំណត់នៅក្នុងការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ តម្រូវឱ្យវិស័យសាធារណៈមានសមត្ថភាពខ្ពស់ ដើម្បីអនុវត្តកំណែទម្រង់ និងផ្តល់សេវា។ ជោគជ័យនៃសំណើអន្តរាគមន៍ទាំងអស់ គឺអាស្រ័យលើការបង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈដែលពឹងផ្អែកលើសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការបង្កើតប្រាក់ចំណូលគ្រប់គ្រាន់ សម្រាប់ចំណាយសាធារណៈសំខាន់ៗ និងសម្រាប់តម្រូវការវិនិយោគ ចំណាយធនធានប្រកបដោយប្រសិទ្ធិភាព និងគណនេយ្យភាព និងរក្សាការងាររដ្ឋបាលសាធារណៈឱ្យមានដំណើរការល្អជាមួយនឹងមន្ត្រីរាជការមានសមត្ថភាព។ ប្រទេសកម្ពុជាបានចាប់ផ្តើមធ្វើការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈការបង្កើនការទទួលខុសត្រូវនិងស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តនៃអ្នកផ្តល់សេវាជួរមុខ។ ការធ្វើឱ្យមានតុល្យភាពជាថ្មីនៃការទទួលខុសត្រូវ តម្រូវឱ្យមានការវិភាជថវិកាសាជាថ្មី និងធនធានមនុស្ស នៅគ្រប់កម្រិតនៃរដ្ឋាភិបាល។

ការកែលម្អកំពុងប្រព្រឹត្តទៅនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស៊ីជម្រៅ រួមជាមួយនឹងកំណែទម្រង់រដ្ឋបាលសាធារណៈជាទូទៅ គឺជាគន្លឹះក្នុងការលើកកម្ពស់សមត្ថភាពសម្រាប់ការផ្តល់សេវាសាធារណៈ។ ទំនើបភាវូបនីយកម្មឧបករណ៍គ្រប់គ្រងព័ត៌មានធនធានមនុស្ស (HR) ក៏នឹងមានសារៈសំខាន់ផងដែរសម្រាប់ការគាំទ្រដល់ការគ្រប់គ្រងសមិទ្ធកម្មរបស់បុគ្គលិក និងមុខងារគ្រប់គ្រងធនធានមនុស្សនៃវិស័យសាធារណៈជារួម។ លើសពីនេះទៀតវិធីសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ រួមជាមួយការលើកកម្ពស់យន្តការ ឱ្យមានការផ្តល់ព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋចំពោះគុណភាពនៃ សេវាដែលបានផ្តល់ នឹងជួយបង្កើនតម្លៃប្រាក់ក្នុងការប្រើប្រាស់ថវិកាសាធារណៈ និងកែលម្អគណនេយ្យភាព និងការត្រួតពិនិត្យ។ ជាចុងក្រោយ គួរកត់សំគាល់ថាចំណុចខ្សោយទាំងឡាយដែលរកឃើញនៅក្នុងសូចនាករសមត្ថភាពស្ថិតិ តម្រូវឱ្យមានការលើកកម្ពស់សមត្ថភាពនៃប្រព័ន្ធស្ថិតិ ក្នុងការជូនដំណឹងអំពីដំណើរការសម្រេចចិត្តផ្អែកលើភស្តុតាង ក៏ដូចជាតាមដាន និងវាយតម្លៃវឌ្ឍនភាពក្នុងការអភិវឌ្ឍន៍ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

# ប្រភពឯកសារយោង


Germanwatch, 2016. Global Climate Risk Index.

IMF, 2016. 2016 Article IV Consultation. IMF Country Report No. 16/340. International Monetary Fund, November 2016, Washington DC.

Inter-Parliamentary Union, 2016. Women in Politics: 2015. Inter-Parliamentary Union, UN Women. Geneva, 10 March 2015.

RGC, 2015a. "PFM Evaluation in Cambodia." Based on the Public Expenditure and Financial Accountability Methodology. Royal Government of Cambodia. September, 2015.

RGC, 2015b. "Climate Change Financing Framework." Royal Government of Cambodia.


សំគាល់: ដើម្បីសម្រួលដល់ការអាន មានតែប្រភពមួយចំនួនប៉ុណ្ណោះដែលត្រូវបានដកស្រង់ ក្នុងផ្នែក *ទិដ្ឋភាពរួម*នេះ។

សម្រាប់ឯកសារគន្លងនិទ្ទេសពេញលេញ សូមអានរបាយការណ៍ពិស្តារស្តីពីការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ ដែលអាចរកបាននៅអាស័យដ្ឋានខាងក្រោម៖
http://documents.worldbank.org/curated/en/620151496155751423/Cambodia-Sustaining-strong-growth-for-the-benefit-of-all

ក្រុមធនាគារពិភពលោក

ការិយាល័យប្រចាំនៅកម្ពុជា
អគារ Exchange Square
ជាន់ទី10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ កម្ពុជា
www.worldbank.org/cambodia